# វិន័យសីល ១០

រៀបរៀងដោយ

**ព្រះធម្មវិបស្សនា សំ ប៊ុនធឿន កេតុធម្មោ**

អធិបតីពុទ្ធមណ្ឌលនិងជាអគ្គនាយកវិបស្សនាធុរៈសិក្សា

នៃព្រះរាជាណាចក្រកម្ពុជា

ផ្សាយចេញពី

**ពុទ្ធមណ្ឌលវិបស្សនាធុរៈនៃព្រះរាជាណាចក្រកម្ពុជា**

**ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល**

រក្សាសិទ្ធិ

ព.ស. គ.ស.

# អារម្ភកថា

ដើម្បីពង្រឹងនូវគុណធម៌នៃការប្រតិបត្តិ ចំពោះត្រៃសិក្ខាដល់គ្រហស្ថ ដែលមានសេចក្តីលះបង់ខ្ពស់ ខ្ញុំបានប្រមែប្រមូលនូវឯកសារនានានិងដកស្រង់នូវខ្លឹមសារដែលមានក្នុងគម្ពីរធម្មបទដ្ឋកថា មង្គលត្ថទីបនី វិសុទ្ធិមគ្គយកមកចងក្រងរៀបរៀងឱ្យកើតជាសៀវភៅឈ្មោះ វិន័យសីល១០ ដើម្បីជាប្រទីបសម្រាប់ជួយបំភ្លឺដល់សីលវន្ត-សីលវតី ក្នុងសម័យមហាសិន្និបាតគ្រូវិបស្សនាធុរៈលើកទី១ ឆ្នាំ២០០២ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៨ ១៩ , ២០ ខែកក្កដា ឆ្នាំ២០០២។ កាលខ្ញុំបានរៀបរៀងនូវសៀវភៅនេះចប់ហើយ ក៏បានប្រគល់ឱ្យគណៈកម្មាធិការវិបស្សនាធុរៈជួយត្រួតពិនិត្យកែសម្រួលនិងបោះពុម្ពឱ្យកើតឡើងសម្រាប់ប្រើប្រាស់ក្នុងព្រះពុទ្ធសាសនា។

ដោយអានុភាពនៃការព្យាយាមនេះ សូមឧទ្ទិសនូវមហាកុសលដូចតទៅ :

-សូមឱ្យអតីតព្រះមហាក្សត្រ បុព្វបុរស វីរជន បញ្ញវន្ត កវីបណ្ឌិត មហាជន ព្រះថេរានុត្ថេរគ្រប់ព្រះអង្គ ដែលបានអស់ជីពជន្មកន្លងទៅ ហើយបានទៅកើតសុគតិភពគ្រប់ៗរូប។

-សូមថ្វាយព្រះរាជកុសលដល់ព្រះមហាក្សត្រនិងព្រះជាយា ព្រមទាំងព្រះរាជវង្សានុវង្ស ប្រកបដោយសេចក្ដីសុខ ផាសុខុមាលភាពមានព្រះជន្មាទីឃាយុជាងរយព្រះវស្សា ដើម្បីបានគង់នៅជាម្លប់ដ៏ត្រជាក់ដល់ពលរដ្ឋខ្មែរតរៀងទៅ ។

សូមថ្វាយព្រះរាជកុសលដល់សម្ដេចព្រះសង្ឃរាជទាំង២គណៈ និងព្រះថេរានុត្ថេរគ្រប់ព្រះអង្គដែលបួសក្នុងព្រះពុទ្ធសាសនា ប្រកបដោយសេចក្ដីសុខ និងសេចក្ដីចម្រើន ជានិរន្តរ៍តរៀងទៅ ។

សូមរំលែកនូវមហាកុសលនេះ ជូនដល់សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់ឋានៈនិងប្រជាពលរដ្ឋទូទាំងព្រះរាជាណាចក្រកម្ពុជានិងក្រៅប្រទេសនៅក្នុងពិភពលោកទាំងមូលសូមឱ្យបានសេចក្ដីសុខ សេចក្ដីចម្រើននិងសុភមង្គលគ្រប់ប្រការ ។

ម្យ៉ាងទៀត សូមឧទ្ទិសមហាកុសលនេះជូនចំពោះបុព្វការីជន មានមាតានិងបិតា គ្រូឧបជ្ឈាយាចារ្យ ព្រះធម្មាចារ្យគ្រប់ព្រះអង្គ ព្រមទាំងញាតកាគ្រប់សន្តាន សូមឱ្យប្រកបតែសម្បត្តិ៣ គឺមនុស្ស ទេវតា និងព្រះនិព្វាន ។

សូមឱ្យព្រះពុទ្ធសាសនារុងរឿងចម្រើន ស្ថិតស្ថេរតាំងនៅក្នុងលោក អស់កាលជាយូរអង្វែងទៅហោង ។

ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃ ទី ១៥ ខែ កក្កដា ព.ស.២៥៤៦

គ.ស.២០០២

ព្រះធម្មវិបស្សនា **សំ~ប៊ុនធឿន** កេតុធម្មោ

អធិបតីពុទ្ធមណ្ឌលនិងជាអគ្គនាយកវិបស្សនាធុរៈសិក្សា

នៃព្រះរាជាណាចក្រកម្ពុជា

# **ធម្មទាន**

## ឧបាសិកា **ស៊ុខ-អ៊ីម** ព្រមទាំងបុត្រ

បានបោះពុម្ព **សៀវភៅវិន័យសីល ១០** សម្រាប់ចែកជូន ដល់មហាជនទូទៅ ។

ដោយអានុភាពនៃបុញ្ញកម្មនេះ សូមឧទ្ទិសមហាកុសលជូន **ព្រះធម្មវិបស្សនា សំ-ប៊ុនធឿន កេតុធម្មោ** និងបុព្វការីជន ទាំងអស់មាន មាតាបិតា ជីដូនជីតា និងគ្រូឧបជ្ឈាយាចារ្យមួយអន្លើ ដោយពពួកញាតិក្នុងសង្សារវដ្តគ្រប់ៗគ្នា ។

សូមអស់លោកដ៏មានគុណទាំងអស់នោះ អញ្ជើញទទួលអនុមោទនាត្រេកអរ ហើយសូមបានសម្រេចនូវឧត្តមប្រយោជន៍ព្រមទាំងបានសោយសុខក្នុងសុគតិភពមានព្រះនិព្វានជាអវសានកុំបីឃ្លៀងឃ្លាតទៅជាប្រការដទៃឡើយ ។

**ព.ស.** **គ.ស.**

# មាតិកា

| លេខរៀង | ឈ្មោះធម៌ | ទំព័រ |
|---|---|---|
| ១- | សេចក្តីផ្តើម | ១០ |
| ២- | ទស្សនៈកម្មផល | ១២ |
| ៣- | ប្រវត្តិសីល១០ | ១២ |
| ៤- | រឿងឧកណ្ឋិតភិក្ខុ | ១៣ |
| ៥- | អត្ថាធិប្បាយសីល១០ | ២២ |
| ៦- | សីល១០ | ២៤ |
| ៧- | សេចក្តីអធិប្បាយសិក្ខាបទ១០ | ២៥ |
| ៨- | អកុសលកម្មបថ | ២៦ |
| | ក-អកុសលកម្មបថ១០:កាយកម្ម៣-វចីកម្ម៤-មនោកម្ម៣ | ២៧ |
| | ខ-អកុសលកម្មបថពិស្តារៈ កាយកម្ម១២-វចីកម្ម១៦ មនោកម្ម១២ | ២៨ |
| ៩- | កុសលកម្មបថ | ៣១ |
| | ក-កុសលកម្មបថ១០ : កាយកម្ម៣-វចីកម្ម៤-មនោកម្ម៣ | ៣១ |

ខ-កុសលកម្មបថពិស្តារ : កាយកម្ម១២- វចីកម្ម១៦-
មនោកម្ម១២.................................................................៣៣
១០- សេចក្តីសង្រួមក្នុងឥន្ទ្រិយទាំង៦........................................៣៣
១១- សេចក្តីអត្ថាធិប្បាយរបស់សេចក្តីសង្រួម..........................៣៤
ក-អាចារៈ និងអនាចារៈ ......................................................៣៦
ខ-អភិសមាចារមាន២.........................................................៣៧
១២- គោចារៈ និងអគោចរៈ......................................................៣៨
១៣- សង្រួម និងមិនសង្រួម.........................................................៤១
ក-សំវរធម៌.........................................................................៤២
ខ-អសំវរធម៌.......................................................................៤២
គ-សេចក្តីអធិប្បាយអំពីសំវរធម៌និងអសំវរធម៌............៤២
១៤- ឃើញភ័យក្នុងទោសបន្តិចបន្តួច........................................៤៨
១៥- លះបង់មិច្ឆាជីវៈ-សមាទានសម្មាជីវៈ...............................៤៩
១៦- ពិចារណានូវគ្រឿងឧបភោគ-បរិភោគឱ្យឃើញ
ត្រឹមតែធាតុ.......................................................................៥២
១៧- បច្ចវេក្ខណវិធី.....................................................................៥៥
ក-ធាតុប្បច្ចវេក្ខណៈ..........................................................៥៥

ខ-បដិកូលប្បច្ចវេក្ខណៈ........................................................៥៨
គ-តង្គណិកប្បច្ចវេក្ខណៈ........................................................៦០
ឃ-អតីតប្បច្ចវេក្ខណៈ........................................................៦៥
១៨- លក្ខណៈវិនិច្ឆ័យក្នុងបច្ចវេក្ខណវិធី....................................៧០
១៩- ដែនរបស់ប្រយោជន៏ក្នុងការប្រើប្រាស់នូវបច្ច័យ............៧២
២០- ការជម្រះសីល........................................................៧៦
២១- ការចម្រើនកម្មដ្ឋាន........................................................៨០
២២- ភាពផ្សេងគ្នារវាងសីល៨ និងសីល១០..............................៨១
២៣- ឧបោសថសីល........................................................៨១
២៣- របៀបស្លៀកពាក់របស់អ្នករក្សាសីល១០-
សីល៨-បាដិហារិយុបោសថ និងសីល៥............................៨១
២៤-កិច្ចវត្ត ........................................................៨៩

# នមស្ការព្រះរតនត្រ័យ

**នមោ តស្សារហន្តស្ស ភគវន្តស្ស តាទិនោ**
**សម្មា សាមំ ច ពុទ្ធស្ស ធម្មេ ចិតវ្ជាទិនោ**

សូមថ្វាយបង្គំឆ្ពោះព្រះអរហន្ត ទ្រង់នាមភគវន្តប្រសើរបវរ
ព្រះអង្គមិនមានព្រះទ័យញាប់ញ័រ ដោយលោកធម៌ទាំង៨ ឡើយ
ទ្រង់ត្រាស់ដឹងធម៌ដោយប្រពៃហើយ ចែកធម៌នោះឱ្យដល់សត្វទាំងពួង ។

**នមោ តស្សេ វធម្មស្ស និយ្យានិកស្ស វដ្តតោ**
**បតេនា នវវីធស្ស ស្វាក្ខាតស្សេ ច សច្ចតោ**

សូមថ្វាយបង្គំឆ្ពោះគុណព្រះធម៌ ស្រង់សត្វនិករចេញចាកសង្សារ
ជាធម៌មានភេទប្រាំបួនប្រការ ដែលសាស្តាចារ្យពោលទុកទូន្មាន
មានព្រះសោតានោះជាប្រធាន មានព្រះនិព្វានជាបរិយោសាន ។

**នមោ អរិយសង្ឃស្ស សព្វិត្វតស្ស សត្ថុនោ**
**កិលេសានុសយេ សព្វេ បហានប្បដិបត្តិយា**

សូមថ្វាយបង្គំឆ្ពោះគុណព្រះសង្ឃ ប្រសើរគ្រប់អង្គ ជាសិស្សសាស្តា
ជាសង្ឃប្រតិបត្តិលះកាត់តណ្ហា ព្រះទ័យជ្រះថ្លា គ្មានសៅហ្មងឡើយ
អនុស័យកិលេសលោកលះអស់ហើយ នឹងឆ្លងដល់ត្រើយគឺព្រះនិព្វាន ។

# ១-សេចក្តីផ្តើម

ពីសម័យដើមមនុស្សទាំងអស់ក្នុងសកលលោក តែងមានការរស់នៅជាក្រុមៗ តាមធម្មតាគេបានកំណត់ហៅថា"កុលសម្ព័ន្ធ"បច្ចុប្បន្នកាលនេះគេប្រើពាក្យហៅថា "ក្រុម"។

ក្រុមនីមួយៗកាលបើរស់នៅផ្តុំគ្នាក៏កើតទៅជាភូមិមួយ កាលបើភូមិច្រើនផ្តុំគ្នាក៏កើតឡើងទៅជាឃុំ ឬ សង្កាត់មួយ ឃុំ ឬ សង្កាត់មានចំនួនច្រើនបូកចូលគ្នាក៏ក្លាយទៅជាស្រុក ឬ ខណ្ឌមួយ កាលបើស្រុក ឬ ខណ្ឌច្រើនរួមគ្នាបានទៅជាខេត្ត ឬ ក្រុងមួយ កាលបើខេត្ត និងក្រុងរួមគ្នាច្រើនគេបញ្ញត្តហៅថា "ប្រទេស" មួយ។

នៅក្នុងសកលលោកយើងនេះមានប្រទេសច្រើនស្ថិតនៅ ហើយមានឈ្មោះហៅផ្សេងៗគ្នា ដូចជាមានឈ្មោះហៅថា ប្រទេសកម្ពុជា វៀតណាម ឡាវ ថៃ ភូមា ឥណ្ឌា។ល។ជាដើម។

ដើម្បីរក្សានូវសណ្តាប់ធ្នាប់ របៀបរៀបរយនៃការរស់នៅក្នុងសង្គមប្រទេសនីមួយៗតែងបង្កើតឡើងនូវច្បាប់ មានច្បាប់រដ្ឋធម្មនុញ្ញជាដើមសម្រាប់គ្រប់គ្រងមនុស្សក្នុងប្រទេសរបស់ខ្លួន។ នៅក្នុងសកលលោកយើងនេះ គ្មានប្រទេសណាដែលគ្មានច្បាប់គ្រប់គ្រងមនុស្សឡើយ គ្រាន់តែ

ច្បាប់នោះមានលក្ខណៈដូចគ្នាខ្លះ និងផ្សេងគ្នាខ្លះ ដោយយោងទៅតាមទំនៀមទម្លាប់ប្រពៃណីសាសនា និងភូមិសាស្ត្រដែនដីនោះប៉ុណ្ណោះ ។

ទោះជាមនុស្សមានទំនៀមទម្លាប់ប្រពៃណីនិងជំនឿសាសនាផ្សេងៗគ្នាយ៉ាងណាក៏ដោយ ក៏គង់មនុស្សទាំងអស់នោះតែងមានសេចក្តីប្រាថ្នាដូចគ្នាគឺ "**សេចក្តីសុខនិងសេចក្តីចម្រើន**" ។

កាលបើមនុស្សក្នុងសកលលោកចង់បានសេចក្តីសុខ-ចម្រើន ដូច្នេះហើយក៏នាំគ្នាស្វែងរកហេតុនៃសេចក្តីសុខ-ចម្រើន នោះគ្រប់ៗរូប ។

បុគ្គលពួកខ្លះដែលប្រកបដោយសេចក្តីល្ងង់ខ្លៅ មិនដឹងរឿងពិតនៃសង្ខារលោក[១] ក៏នាំគ្នាសាងតែបាបកម្ម មានកាប់សម្លាប់គ្នា ដណ្តើមយកទ្រព្យគ្នាជាដើម ដែលជាហេតុនាំឱ្យអសកម្មដល់សង្គម នាំនូវសេចក្តីទុក្ខដែលជាអំពើផ្ទុយនឹងអ្វីដែលមនុស្សចង់បាន ។

បុគ្គលពួកខ្លះដែលបានទទួលនូវការអប់រំច្រើនអំពីសំណាក់បណ្ឌិត ក៏មានគំនិតល្អ ជ្រើសរើសការងារប្រព្រឹត្តតែអំពើដែលនាំមកប្រយោជន៍ដល់សង្គម មានប្រកបដោយមុខរបរធ្វើអាជីវកម្ម ប្រកបដោយសុចរិតធម៌និងគតិយុត្តជាដើម ។

---

[១] :សំដៅយកកម្មតាក់តែងឱ្យផ្សេងគ្នា ។

## ២.ទស្សនៈកម្មផល

ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ទ្រង់បានជ្រាបច្បាស់នូវដំណើរវិលវល់របស់សត្វទាំងឡាយក្នុងសង្សារវដ្តថា "ពពួកសត្វទាំងអស់តែងប្រព្រឹត្តទៅតាមអំណាចនៃកម្ម គឺកម្មជាអ្នកចាត់ចែង" ដូចពុទ្ធដីកាលោកពោលថា " **កល្យាណការី កល្យាណំ បាបការី ច បាបកំ សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ** " អ្នកធ្វើនូវអំពើបុណ្យរមែងបានសេចក្តីល្អ អ្នកធ្វើនូវអំពើបាបរមែងបានសេចក្តីអាក្រក់ សេចក្តីស្អាតនិងមិនស្អាតគឺខ្លួនជាអ្នកធ្វើ បុគ្គលដទៃមិនគប្បីជម្រះជនដទៃឱ្យស្អាតបានឡើយ ។

## ៣.ប្រវត្តិសីល១០

គ្រហស្ថដែលរក្សាសីល១០នេះ មិនមែនមានតែក្នុងបច្ចុប្បន្នកាលនេះទេ ប្រាកដជានឹងមានតាំងអំពីសម័យពុទ្ធកាលមកម្ល៉េះ ព្រោះមានរឿងឧក្កណ្ឋិតភិក្ខុ ក្នុងគម្ពីរធម្មបទដ្ឋកថាភាគ២ ត្រង់ចិត្តវគ្គវណ្ណនាពីទំព័រ២១៣ រហូតដល់ទំព័រ២១៧ មានសេចក្តីបញ្ជាក់យ៉ាងច្បាស់លាស់ ។

## ៤-រឿងឧក្កណ្ឋិតភិក្ខុ

កាលព្រះសាស្តាកំពុងគង់នៅក្នុងក្រុងសាវត្ថី មានសេដ្ឋីបុត្តម្នាក់ចង់រួចចាកផុតពីសេចក្តីទុក្ខ ក៏បានចូលទៅកាន់សំណាក់ព្រះថេរៈមួយអង្គដែលចូលមកកាន់ត្រកូលរបស់ខ្លួន ហើយក៏សួរព្រះថេរៈនោះថា "បពិត្រលោកម្ចាស់ តើខ្ញុំព្រះករុណាត្រូវធ្វើដូចម្តេចដើម្បីរួចចាកពីសេចក្តីទុក្ខ? ព្រះថេរៈអង្គនោះក៏ពោលថា "បើអ្នកចង់រួចចាកពីសេចក្តីទុក្ខ ចូរអ្នកចំណាយទ្រព្យសម្បត្តិរបស់ខ្លួន ធ្វើនូវទាន មានការឱ្យនូវចីវរទានជាដើម"។

សេដ្ឋីបុត្តក៏បានបរិច្ចាគនូវទ្រព្យសម្បត្តិដែលខ្លួនប្រកបអាជីវកម្មបានមកបូជាចំពោះព្រះពុទ្ធសាសនា។ លុះដល់បានធ្វើទានរួចហើយក៏សួរនូវបញ្ហានោះនឹងព្រះថេរៈម្តងទៀត។ ព្រះថេរៈលោកបានពោលថាៈ

**អាវុសោ តីណិ សរណានិ គណ្ហ បញ្ច សីលានិ អដ្ឋ សីលានិ គណ្ហាហិ ។**

មានសេចក្តីថាៈ ម្នាលអ្នកដ៏មានអាយុអ្នកចូរកាន់យកនូវព្រះត្រៃ-សរណគមន៏ ហើយរក្សាសីល៥ សីល៨ ចុះ។

សេដ្ឋីបុត្តនោះ កាលបើបានរក្សាសីល៥ សីល៨ មួយអន្លើដោយត្រៃសរណគមន៍ផង ក៏ពុំទាន់អស់នូវចំណង់ក្នុងផ្លូវប្រតិបត្តិឡើយ ក៏ដណ្តឹងសួរនឹងព្រះថេរៈអំពីការធ្វើដូចម្តេចដើម្បីឱ្យឆាប់រួចចាកពីសេចក្តីទុក្ខ។

ព្រះថេរៈក៏ឱ្យឱវាទថា **តេនហិ ទស សីលានិ គណ្ហាហិ** មានសេចក្តីថា បើដូច្នោះអ្នកចូររក្សាសីល ១០បន្ថែមទៀតចុះ។ សេដ្ឋីបុត្តនោះក៏រក្សានូវសីល១០ថែមទៀត។ ចាប់តាំងពីថ្ងៃនោះមកសេដ្ឋីបុត្តក៏បានឈ្មោះប្រាកដថា អនុបុព្វសេដ្ឋីបុត្ត តទៅ។

លុះបានរក្សាសីល១០រួចហើយ ក៏នៅតែមិនទាន់អស់ឆន្ទៈក្នុងផ្លូវប្រតិបត្តិសោះ ក៏សួរនឹងព្រះថេរៈនូវផ្លូវប្រតិបត្តិដ៏លើសជាងនេះ ដើម្បីរលាស់ចោលនូវសេចក្តីទុក្ខតទៅទៀត។

ព្រះថេរៈបានឱ្យឱវាទថា បើអ្នកមានសេចក្តីប្រាថ្នាដើម្បីបំពេញនូវបុញ្ញកម្មដ៏លើសលុប ដូច្នោះចូរអ្នកបំពេញនូវបព្វជាចុះ។

ចាប់តាំងពីថ្ងៃនោះមក អនុបុព្វសេដ្ឋីបុត្តនោះក៏បានលះបង់នូវភេទជាគ្រហស្ថ ហើយក៏ចូលបួសបំពេញឧបសម្បទជាភិក្ខុ ក្នុងព្រះពុទ្ធសាសនាតទៅ។

កាលបើសាងផ្នួសហើយភិក្ខុអង្គនោះលោកមានព្រះធម្មាពីរព្រះអង្គ ១ព្រះអង្គលោកទ្រទ្រង់ព្រះវិន័យ ១ព្រះអង្គទៀតទ្រទ្រង់ព្រះអភិធម្ម ។

លោកអាចារ្យដែលទ្រទ្រង់ព្រះវិន័យ ក៏ទូន្មានភិក្ខុនោះដោយកិច្ចប្រតិបត្តិដ៏តឹងរឹងមានពាក្យថា"កិច្ចនេះសមណៈមិនត្រូវធ្វើ កិច្ចដូច្នេះសមណៈត្រូវធ្វើជាដើម" ។

រីឯលោកអាចារ្យដែលទ្រទ្រង់ព្រះអភិធម្ម ក៏បានសម្ដែងធម្មដ៏ល្អិតសុខុមទូន្មានភិក្ខុអង្គនោះដែរ ។ កាលបើភិក្ខុនោះ បានស្ដាប់នូវឱវាទរបស់លោកអាចារ្យទាំងពីររូបហើយ ក៏គិតពិចារណាក្នុងចិត្តតែម្នាក់ឯងថា"អើហ្ន៎ អញមកបួសនេះប្រាថ្នាដើម្បីរួចចាកសេចក្ដីទុក្ខពិត តែថាធម្មវិន័យក្នុងសាសនានៃព្រះអង្គ អញមិនងាយប្រតិបត្តិបានឡើយ ។ ចំណែកខាងវិន័យដែលលោកអាចារ្យបានទូន្មានហើយតឹងរឹងណាស់ ហើយច្រើនទៀតរកតែលើកដៃលើកជើងក៏មិនរួច ត្រង់នេះខុស ត្រង់នោះត្រូវ ចំណែកខាងអភិធម្មវិញ ដែលលោកអាចារ្យសម្ដែងហើយ ជាធម៌ល្អិត សុខុមរកតែយល់ដឹងសេចក្ដីក៏មិនបាន ។ ណ្ហើយចុះ អញមិនអាចនៅជាភេទបព្វជិតគោរពប្រតិបត្តិធម៌និងវិន័យបានឡើយ អញនឹងលាចាក សិក្ខាបទពីភេទបព្វជិតទៅជាភេទគ្រហស្ថវិញ ។ ការនៅជាឃរាវាស ក៏នឹងអាចប្រតិបត្តិធម៌

ឱ្យផុតចាកពីសេចក្ដីទុក្ខបានដែរ។ កាលបើភិក្ខុនោះ មានសេចក្ដីត្រិះរិះដូច្នេះហើយក៏ឈប់ចម្រើនកម្មដ្ឋានឈប់រៀនទូវឧទ្ទេស ។ ក្នុងសម័យដែលភិក្ខុមានចិត្តមិនត្រេកអរក្នុងការប្រព្រឹត្តនូវព្រហ្មចរិយធម៌ភិក្ខុនោះក៏មានកាយស្គមស្គាំងមានសរសៃរវាម គ្របដណ្ដប់ឆ្អឹងកើតរោគលឿងស្លេកស្លាំង។ កាលបើមានភិក្ខុ ឬ សាមណេរសួរលោក១ក៏ពោលប្រាប់តាមដំណើរពិត។ ភិក្ខុ ឬសាមណេរបានដឹងរឿងនោះហើយ ក៏ប្រាប់ដល់ព្រះថេរៈជាអាចារ្យទាំងពីរអង្គ។ លោកអាចារ្យទាំងពីរ កាលបើដឹងរឿងនោះហើយ ក៏នាំភិក្ខុអង្គនោះយកទៅថ្វាយព្រះដ៏មានព្រះភាគដើម្បីសូមឱ្យព្រះអង្គទ្រង់ព្រះរាជទានប្រោសប្រាណ។

លំដាប់នោះ ព្រះបរមសាស្ដាចារ្យទ្រង់បានសាកសួរដល់ឧក្កណ្ឋិតភិក្ខុហើយទ្រង់ជ្រាបនូវហេតុផលសព្វគ្រប់ ទើបព្រះអង្គទ្រង់មានព្រះបន្ទូលសួរភិក្ខុថា៖ម្នាលភិក្ខុ តើអ្នកអាចសិក្សាតែធម៌មួយប៉ុណ្ណោះបានដែរឬទេ?

ភិក្ខុនោះឆ្លើយតបថា ៖ ព្រះករុណាម្ចាស់ បើត្រឹមតែធម៌មួយបាន។ ម្នាលភិក្ខុបើដូច្នេះចូរអ្នករក្សាចិត្តតែមួយ កុំឱ្យអកុសលធម៌មានរាគៈជាដើមគ្របសង្កត់ចិត្តបាន។ ហើយព្រះបរមសាស្ដាចារ្យទ្រង់ពោលនូវគាថា

បន្តថា : **សុទុទ្ទសំ សុនិបុណំ យត្ថកាមនិបាតិនំ ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ។**

មានសេចក្តីថា : អ្នកប្រាជ្ញគប្បីរក្សានូវចិត្តដែលជនមើលឃើញបាន ដោយកម្រក្រៃលែង ដែលតែងមានកិរិយាមិនរមិលមើលនូវធម៌ទាំងឡាយមានជាតិជាដើម ហើយធ្លាក់ចុះក្នុងទីដែលបុគ្គលគប្បីបាន និងមិនបាន គួរនិងមិនគួរជាប្រក្រតីរឿយៗ។ ចិត្តដែលជនគ្រប់គ្រងបានហើយ តែងនាំមកនូវសេចក្តីសុខ។ នៅទីបំផុតនៃព្រះធម៌ទេសនា ភិក្ខុអង្គនោះក៏បានសម្រេចនូវសោតាបត្តិផលក្នុងទីនោះឯង។ សូម្បីជនដទៃក្រៅពីភិក្ខុអង្គនោះ ក៏បានលុះទៅក្នុងមគ្គផលទាំងឡាយ មានសោតាបត្តិផលជាដើមផងដែរ។

លើកនិទាន ឧក្កណ្ឋិតភិក្ខុ មកបញ្ជាក់ឱ្យឃើញថា : សីល១០ (អតិរេកសីល ឬ និយមសីល) នេះ ក្នុងសម័យព្រះដ៏មានព្រះភាគ កាលព្រះអង្គគង់ធរមាននៅឡើយ ក៏មានពុទ្ធបរិស័ទគេធ្លាប់រក្សាហើយដែរ។

មានសេចក្តីមួយកន្លែងទៀត ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់អំពីសីល១០ ត្រង់ **សញ្ញយស្សានាគមនវត្ថុ** នៃយមកវគ្គវណ្ណនាក្នុងគម្ពីរធម្មទដ្ឋកថាភាគ១ ដែលពោលអំពើបុព្វកម្មរបស់ភិក្ខុទាំងបីគឺ

ឧរុវេលកស្សប១ គយាកស្សប១ នទីកស្សប១។ មាននិទានដូចតទៅ : សម័យនោះព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ដែលជាអារាម របស់ស្ដេចពិម្ពិសារកសាងថ្វាយ ទ្រង់បានសម្ដែងនូវបុព្វកម្មរបស់ភិក្ខុទាំង បីមាន ឧរុវេលកស្សបជាដើម។

មានសេចក្ដីថា : ភិក្ខុទាំង៣អង្គនេះ ដែលនាំឱ្យបានសម្រេចនូវព្រះ អរហត្តផលក្នុងជាតិនេះ ដោយបានកសាងបុណ្យកុសលតម្កល់ទុកតាំងពី ក្នុងសម័យព្រះពុទ្ធទ្រង់ព្រះនាម "ផុស្សៈ" ក្នុងកប្ប៩២ កន្លងទៅហើយ ម្ល៉េះ។ក្នុងសម័យនោះ កស្សបទាំងបី បានយកកំណើតកើតជាកូនស្ដេច ព្រះនាមមហិន្ទ ត្រូវជាបងប្អូនបង្កើតនឹងគ្នា។ ព្រះមហិន្ទនោះ មានព្រះ ពុទ្ធព្រះនាមផុស្សៈ ជាព្រះរាជបុត្តច្បង ដូច្នេះកស្សបទាំងនោះ ក៏ត្រូវជា ប្អូនប្រុសបង្កើតរបស់ព្រះពុទ្ធព្រះនាមផុស្សៈដែរ[២]។

ព្រះមហិន្ទរាជ លោកជ្រះថ្លានឹងព្រះពុទ្ធជាបុត្តនោះយ៉ាងខ្លាំងក្រៃ លែង រហូតដល់ថ្នាក់បវារណាព្រះពុទ្ធព្រះនាមផុស្សៈ ឱ្យទ្រង់ទទួលចង្ហាន់ បិណ្ឌបាតដែលជារបស់ខ្លួនតែមួយប៉ុណ្ណោះដរាបដល់អស់ព្រះជន្ម មិនឱ្យ

---

[២] :មាតាទីទៃ។

ទ្រង់និមន្តទៅគោចរបិណ្ឌបាតក្នុងផ្ទះដទៃទៀយ ។ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមផុស្សៈ ដើម្បីបំពេញករុណាធមិដល់ពុទ្ធបិតា ក៏ទ្រង់ទទួលយល់ព្រមតាមការបវារណារបស់ស្តេចមហិន្ទ ។ រីឯព្រះរាជបុត្តទាំងបីអង្គ ក៏មានសេចក្តីជ្រះថ្លាចំពោះព្រះពុទ្ធជាបងដែរ ហើយចង់ធ្វើបុណ្យថ្វាយចង្ហាន់បិណ្ឌបាតដូចជាបិតារបស់ខ្លួន ក៏ប៉ុន្តែគ្មានឱកាសដើម្បីថ្វាយចង្ហាន់បិណ្ឌបាតដល់ព្រះពុទ្ធឡើយ ព្រោះបិតាមិនអនុញ្ញាត ។

សម័យខាងក្រោយមកនៅតាមជនបទនៃប្រទេស កើតកោលាហលវឹកវរដោយសត្រូវ ។ ព្រះមហិន្ទរាជា ក៏ប្រើព្រះរាជបុត្តទាំងបីដែលជាមេទ័ពដ៏ពូកែ ព្រមទាំងកងទ័ពដែលជាបរិវារទៅបង្ក្រាបសត្រូវ ។ មេទ័ពទាំងបី នោះកូនទី១មានកងទ័ពជាបរិវារចំនួន៥00រូប កូនទី២មានកងទ័ពជាបរិវារចំនួន៣00រូប រីឯកូនទី៣មានកងទ័ពជាបរិវារចំនួន២00រូប ។ មេទ័ពទាំងបី និងបរិវារចំនួន១,000នាក់ ក៏បានទៅបង្ក្រាបសត្រូវមានជ័យជំនះហើយ ក៏ត្រឡប់មកកាន់រាជបុរីរបស់ខ្លួនវិញ ។ ព្រះមហិន្ទរាជា កាលបើព្រះរាជបុត្រទាំងបីបានឈ្នះសង្គ្រាមហើយ ក៏មានព្រះហឫទ័យរីករាយសប្បាយហើយក៏ប្រទានពរដល់ព្រះរាជបុត្តទាំងបី ។ ក្នុងកាលនោះព្រះរាជបុត្តទាំងបីបានសុំសំណូមពរធ្វើទាន ប្រគេនចង្ហាន់បិណ្ឌ

បាតដល់ព្រះពុទ្ធជាបងអស់កាលជានិច្ច តែបិតាមិនអនុញ្ញាតឱ្យ។ កាលបើមិនបានទទួលការអនុញ្ញាតឱ្យថ្វាយទានជានិច្ចដល់ព្រះពុទ្ធជាបង ក៏សុំការឱ្យទានត្រឹមតែ៧ឆ្នាំ ក៏នៅតែមិនបានទៀត សុំត្រឹម៦ឆ្នាំ ៥ឆ្នាំ ៤ឆ្នាំ ៣ឆ្នាំ ២ឆ្នាំ ១ឆ្នាំ ក៏នៅតែមិនបានក៏សុំចុះនៅត្រឹម ៧ខែ ៦ខែ ៥ខែ ៤ខែ ក៏នៅតែមិនបាន។ ព្រះមហិន្ទរាជទ្រង់បានអនុញ្ញាតឱ្យព្រះរាជបុត្តទាំងបី ដើម្បីធ្វើទានប្រគេនចង្ហាន់បិណ្ឌបាតដល់ព្រះពុទ្ធព្រះនាម ផុស្សៈ ចំនួន១ខែម្នាក់ប៉ុណ្ណោះ។ ព្រះរាជបុត្តទាំងបីកាលបើបិតាបានអនុញ្ញាតឱ្យខ្លួនធ្វើទានដល់ព្រះពុទ្ធ ចំនួន១ខែម្នាក់ៗដូច្នេះហើយក៏មានចិត្តត្រេកអរ ហើយក៏បានពោលនឹងនាយកាន់ឃ្លាំង និងនាយស្មៀនកាន់បញ្ជីដូច្នេះថា ៈ

**មយំ ឥមំ តេមាសំ ទស សិលានិ គហេត្វា ទ្វេ កាសាយានិ និវាសេត្វា សត្ថារ សហវាសំ វសិស្សាម តុម្ហេ ឯត្តកន្តាម ទានវត្តំ គហេត្វា ទេវសិកំ នវុតិសហស្សានំ ភិក្ខូនញ្ច យោធសហស្សស្ស ច នោ សព្វំ ខាទនីយភោជនីយំ**

## សំវត្តេយ្យាថ មយំ ហិ ឥតោ បដ្ឋាយ ន កិញ្ចិ វត្តាម[៣] ៗ

មានសេចក្តីថា : យើងកាន់យកនូវសីល១០ ស្លៀកដណ្តប់សំពត់កាសាយៈ[៤] ចំនួន១គូ ហើយចាំព្រះវស្សាជាមួយព្រះដ៏មានព្រះភាគរយៈពេល៣ខែ។ ដូច្នេះអ្នកទាំងឡាយចូរកាន់នូវទានវត្ត ឈ្មោះថាមានប្រមាណប៉ុណ្ណោះ អ្នកទាំងឡាយគប្បីធ្វើនូវអាហារភោជនប្រគេនដល់ព្រះភិក្ខុសង្ឃមានចំនួន៩0ពាន់អង្គផង ជូនដល់យោធាចំនួន១000រូបផង រៀងរាល់ថ្ងៃព្រោះថាចាប់ផ្តើមតាំងពីថ្ងៃនេះទៅ យើងឈប់និយាយស្តីអ្វីទៀតហើយ។

កាលបើព្រះរាជបុត្តទាំង៣បានពោលផ្តាំជាមួយនាយឃ្លាំងនិងនាយស្មៀនរួចហើយ ក៏ស្លៀកដណ្តប់សំពត់កាសាយៈ១គូរៀងៗខ្លួនហើយក៏សមាទានសីល ចម្រើនកម្មដ្ឋាន អាស្រ័យនៅចាំព្រះវស្សាជាមួយព្រះសាស្តារហូតដល់កាលកំណត់របស់ខ្លួន ទើបបានដាក់ពីសីល១0នោះវិញ។ ការចាត់ចែងក្នុងការឱ្យទាននិងការរក្សាសីល១0នេះឯង ជាបុញ្ញកម្ម

---

[៣] :ធម្មបទដ្ឋកថាភាគ១ ត្រង់ទំព័រ១៤៦។

[៤] :សំពត់ដែលជ្រលក់ហើយដោយទឹកអម្ចត់។

របស់ព្រះថេរៈទាំងបីមានឧរុវេលកស្សបជាដើម នឹងបានជាឧបនិស្ស័យបានសម្រេចនូវព្រះអរហត្តផលក្នុងសម័យនៃព្រះបរមសាស្ដាចារ្យ ទ្រង់ព្រះនាមសមណគោតមនៃយើងនេះ។

ការនាំនូវមករឿងនិទានទាំង២មកតម្កល់ទុកក្នុងសៀវភៅនេះដើម្បីទុកជាភស្តុតាងបញ្ជាក់ឱ្យឃើញថា សីល១០ ជាសីលមួយប្រាកដជាសីលដែលពុទ្ធបរិស័ទ( គ្រហស្ថ) គេរក្សាតាំងពីសម័យបុរាណកាល[៥] មក។សីល១០នេះក្នុងទីខ្លះហៅថា អតិរេកសីល ឬ និយមសីលដូច្នេះក៏បាន។

## ៥-អត្ថាធិប្បាយសីល១០

អតិរេកសីលមានន័យថា សីលរបស់គ្រហស្ថដែលមានអង្គលើសមួយដ៏ក្រៃលែង។ សីល១០ មានសិក្ខាបទ១០ លើសពីសីល៨ ព្រោះសីល៨បើគិតជាសិក្ខាបទដែលមិនបូកបញ្ចូលគ្នា មាន៩សិក្ខាបទ។ តែបើបូកបញ្ចូលគ្នាត្រង់សិក្ខាបទ **នច្ចគីតវាទិត វិសូកទស្សនា វេរមណី** និង **មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី** រួមទៅត្រូវ៨សិក្ខាបទ។ សីល១០ ដែលមានសិក្ខាបទលើស

---

[៥] :សម័យព្រះពុទ្ធគង់ធរមាន។

សីល៨នោះ គឺសិក្ខាបទ **ឧច្ចាសយនមហាសយនា វេរមណី** ហ្នឹងឯង។

តាមការវិនិច្ឆ័យពិត សីល១០មានសិក្ខាបទ១០ សីល៨មានសិក្ខាបទ៨បើញែកចេញឱ្យពិស្តារមានសិក្ខាបទ៩។

និយមសីល មានន័យថា : សីលដែលគ្រហស្ថសមាទានមានកំណត់ទៅតាមការនិយមរាប់អាន។

បើគ្រហស្ថគេមានសទ្ធាក្នុងការរក្សាសីល១០នោះ កន្លះខែក្តី ១ខែក្តី ឬ២ខែក្តី ៣ខែក្តី ៦ខែក្តី ១ឆ្នាំក្តី ឬ១ជីវិតក្តី ក៏គេរក្សាតាមការកំណត់របស់គេនោះចុះ។ បើតាមរឿងកស្សបទាំងបី មានឧរុវេលកស្សបជាដើម ដែលបានយកកំណើតកើតជាព្រះរាជបុត្ររបស់ព្រះមហិន្ទ ក្នុងសម័យពុទ្ធកាលគឺកាលនៃព្រះពុទ្ធព្រះនាមផុស្សៈដែលព្រះបរមសាស្តាចារ្យនៃយើង ទ្រង់លើកឡើងសម្តែងប្រាប់ដល់ភិក្ខុទាំងឡាយ ព្រះរាជបុត្តទាំងបីនោះ បានកំណត់ការរក្សាសីល១០ ចំនួន៣ខែ ដោយព្រះរាជបិតានៃខ្លួនបាន អនុញ្ញាតឱ្យប៉ុណ្ណឹងឯង។ សីលដែលបុគ្គលសមាទានតាមកំណត់កាលនៃខ្លួនហ្នឹងឯង ហៅថា និយមសីល។ សីល១០ របស់គ្រហស្ថ ជាសីលផ្នែក

មួយដែលមានលក្ខណៈប្រសើរ វិសេសវិសាលជាងសីល[៦] របស់គ្រហស្ថទាំងឡាយ ។ សីលនេះពុទ្ធសាសនិកជន ក៏មានសទ្ធាជ្រះថ្លានាំគ្នារក្សាតាំងអំពីសម័យពុទ្ធកាលរៀងរាបជាហូរហែ ដរាបមកដល់សម័យបច្ចុប្បន្នកាលនេះ។ គ្រាន់តែមានភាពប្លែកគ្នាខ្លះ ដោយយុគសម័យខ្លះក៏សម្បូណ៌អ្នករក្សាសីល១០ ហើយយុគសម័យខ្លះ ក៏មានមនុស្សចំនួនតិចរក្សាសីល១០ប៉ុណ្ណោះ ។

## ៦.សីល១០

សាធុជនដែលរក្សានូវសីល១០ គប្បីរក្សានូវសិក្ខាបទ១០ លះបង់នូវអកុសលកម្មបថ១០ ឬ ៤០ គោរពប្រតិបត្តិតាមតែកុសលកម្មបថ១០ ឬ ៨០ ហើយគប្បីធ្វើនូវសេចក្តីសង្រួមក្នុងឥន្ទ្រិយទាំង៦ មានចក្ខុន្ទ្រិយជាដើមប្រព្រឹត្តនូវអាចារ និងគោចរ ឱ្យបានសមរម្យជាអ្នកឃើញភ័យ សូម្បីក្នុងទោសបន្តិចបន្តួចលះបង់នូវមិច្ឆាជីវៈ ហើយសមាទានយកតែសម្មាជីវៈពិចារណានូវគ្រឿងបរិភោគ និងឱ្យឃើញត្រឹមតែធាតុ គប្បីជម្រះនូវសីលហើយចម្រើនកម្មដ្ឋានតរៀងទៅ ។

[៦] :សីល៥-សីល៨ ។

## ៧_សេចក្តីអត្ថាធិប្បាយ សិក្ខាបទ១០

**១-បាណាតិបាតា វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាញ៉ាំងសត្វមានជីវិតឱ្យធ្លាក់ចុះគន្លង គឺសម្លាប់សត្វ។

**២-អទិន្នាទានា វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា។

**៣-អព្រហ្មចរិយា វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម។

**៤-មុសាវាទា វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

**៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** : ចេតនា ជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ។

**៦-វិកាលភោជនា វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស។

**៧-នច្ចគីតវាទិតវិសូកទស្សនា វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយារាំនិងច្រៀងនិងប្រគំ និងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌។

**៨-មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាទ្រទ្រង់នូវប្រដាប់តាក់តែងស្អិតស្អាង (រាងកាយ) ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

**៩-ឧច្ចាសយនមហាសយនា វេរមណី** : ចេតនា ជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណនិងទីសេនាសនៈដ៏ប្រសើរ ។

**១០-ជាតរូបរជតប្បដិគ្គហនា វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាទទួលកាន់យកនូវមាសនិងប្រាក់ដោយខ្លួនឯង ឬ ប្រើអ្នកដទៃឱ្យទទួលកាន់យក ហើយត្រេកអរចំពោះមាសនិងប្រាក់នោះ ។

អ្នករក្សាសីល១០ ត្រូវរក្សាសិក្ខាបទទាំង១០នេះឱ្យបានបរិសុទ្ធទទឹមនឹងការរក្សាសិក្ខាបទនេះ អ្នករក្សាសីល១០ ត្រូវប្រព្រឹត្តវៀរចាកគន្លងនៃអំពើអាក្រក់ ដែលលោកហៅថា អកុសលកម្មបថ ហើយសមាទានរក្សាគោរពប្រតិបត្តិតាមគន្លងនៃអំពើដ៏ល្អ ដែលលោកហៅថា កុសលកម្មបថ ។

## ៨-<u>អកុសលកម្មបថ</u>

អកុសលកម្មបថពោលដោយសង្ខេបមាន១០ បើពោលដោយពិស្តារមាន៤០ ។

## ក- **អកុសលកម្មបថ១០**

អកុសលកម្មបថនេះ ចែកជា កាយកម្មមាន៣ វចីកម្មមាន៤ និងមនោកម្មមាន៣ ។

### **កាយកម្ម ៣យ៉ាង**

**១-បាណាតិបាតា** : កិរិយាសម្លាប់សត្វដោយកាយរបស់ខ្លួន ឬ ប្រើគេឱ្យសម្លាប់ដោយវាចា ។

**២-អទិន្នាទានំ** : កិរិយាលួចលាក់ ឆក់ដណ្តើមទ្រព្យគេ ដោយកាយរបស់ខ្លួន ឬ ប្រើគេឱ្យលួចលាក់ឆក់ដណ្តើមដោយវាចា ។

**៣-កាមេសុមិច្ឆាចារោ** : កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវន នឹងស្រ្តីដែលមានគេហួងហែងរក្សា ។

### **វចីកម្ម ៤យ៉ាង**

**១-មុសាវាទោ** : កិរិយាពោលនូវពាក្យកុហក ។

**២-បិសុណាវាចា** : កិរិយាពោលនូវពាក្យញុះញង់ស៊កសៀត បំបែកបំបាក់អ្នកដទៃ ។

**៣-ផរុសវាចា** : កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ។

**៤-សម្ផប្បលាបោ** : កិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍។

**<u>មនោកម្ម ៣យ៉ាង</u>**

**១-អភិជ្ឈា** : ចិត្តសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឱ្យបានមកជាទ្រព្យរបស់ខ្លួន។

**២-ព្យាបាទោ** : ចិត្តចងគំនុំគុំគួន គឺប៉ងនឹងឱ្យអ្នកដទៃដល់នូវសេចក្តីវិនាស។

**៣-មិច្ឆាទិដ្ឋិ** : គំនិតយល់ខុស ហើយប្រកាន់ឡើងថាជាត្រូវ។

ខ- **<u>អកុសលកម្មបថពិស្តារ</u>**

អកុសលកម្មបថពិស្តារមាន ៤០ ចាត់ជាកាយកម្មមាន ១២ វចីកម្ម ១៦ និងមនោកម្ម ១២។

**<u>កាយកម្ម១២:</u>**

១-កិរិយា សម្លាប់សត្វមានជីវិតដោយខ្លួនឯង។

២-កិរិយា ប្រើគេឱ្យសម្លាប់សត្វមានជីវិត។

៣-កិរិយា ពេញចិត្តក្នុងការសម្លាប់សត្វមានជីវិត។

៤-កិរិយា ពិពណ៌នាសរសើរគុណនៃការសម្លាប់សត្វមានជីវិត។

៥-កិរិយា កាន់យកទ្រព្យដែលម្ចាស់គេមិនបានឱ្យដោយខ្លួនឯង។

៦-កិរិយា ប្រើគេឱ្យកាន់យកទ្រព្យដែលម្ចាស់គេមិនបានឱ្យ។

៧-កិរិយា ពេញចិត្តក្នុងការកាន់យកទ្រព្យដែលម្ចាស់គេមិនបានឱ្យ ។

៨-កិរិយា ពិពណ៌នាសររសើរគុណនៃការកាន់យកទ្រព្យដែលម្ចាស់គេមិនបានឱ្យ ។

៩-កិរិយា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយដោយខ្លួនឯង ។

១០-កិរិយា ប្រើគេឱ្យប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

១១-កិរិយា ពេញចិត្តក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

១២-កិរិយា ពិពណ៌នាសរសើរគុណនៃការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

## វចីកម្មមាន១៦:

១-កិរិយា និយាយកុហកដោយខ្លួនឯង ។

២-កិរិយា ប្រើគេឱ្យនិយាយកុហក ។

៣-កិរិយា ពេញចិត្តក្នុងការនិយាយកុហក ។

៤-កិរិយា ពិពណ៌នាសរសើរគុណនៃការនិយាយកុហក ។

៥-កិរិយា និយាយពាក្យញុះញង់ដោយខ្លួនឯង ។

៦-កិរិយា ប្រើគេឱ្យនិយាយញុះញង់ ។

៧-កិរិយា ពេញចិត្តក្នុងការនិយាយញុះញង់ ។

៨-កិរិយា ពិពណ៌នាសរសើរគុណនៃការនិយាយញុះញង់ ។

៩-កិរិយា និយាយពាក្យអាក្រក់ដោយខ្លួនឯង ។

១០-កិរិយា ប្រើគេឱ្យនិយាយពាក្យអាក្រក់ ។

១១-កិរិយា ពេញចិត្តក្នុងការនិយាយពាក្យអាក្រក់ ។

១២-កិរិយា ពិពណ៌នាសរសើរគុណនៃការនិយាយពាក្យអាក្រក់ ។

១៣-កិរិយា និយាយពាក្យរោយរាយដោយខ្លួនឯង ។

១៤-កិរិយា ប្រើគេឱ្យនិយាយពាក្យឥតប្រយោជន៍ ។

១៥-កិរិយា ពេញចិត្តក្នុងការនិយាយពាក្យឥតប្រយោជន៍ ។

១៦-កិរិយា ពិពណ៌នាសរសើរគុណនៃការនិយាយពាក្យឥតប្រយោជន៍ ។

## មនោកម្មមាន១២

១-កិរិយា សម្លឹងរំពៃចង់បានទ្រព្យរបស់គេដោយខ្លួនឯង ។

២-កិរិយា ប្រើគេឱ្យសម្លឹងរំពៃចង់បានទ្រព្យរបស់គេ ។

៣-កិរិយា ពេញចិត្តក្នុងការសម្លឹងរំពៃចង់បានទ្រព្យរបស់គេ ។

៤-កិរិយា ពិពណ៌នាសរសើរគុណនៃការសម្លឹងរំពៃចង់បានទ្រព្យរបស់ គេ ។

៥-កិរិយា ចងចិត្តគុំកួនគេដោយខ្លួនឯង ។

៦-កិរិយា ប្រើគេឱ្យចងចិត្តគុំកួនគេ ។

៧-កិរិយា ពេញចិត្តក្នុងការចងចិត្តគុំកួនគេ ។

៨-កិរិយា ពិពណ៌នាសរសើរគុណនៃការចងចិត្តគុំកួនគេ។

៩-កិរិយា ឃើញខុសចាកគន្លងធម៌ដោយខ្លួនឯង។

១០-កិរិយា ប្រើគេឱ្យឃើញខុសចាកគន្លងធម៌។

១១-កិរិយា ពេញចិត្តក្នុងការឃើញខុសចាកគន្លងធម៌។

១២-កិរិយា ពិពណ៌នាសរសើរគុណនៃការឃើញខុសចាកគន្លងធម៌។

## ៩-កុសលកម្មបថ

កុសលកម្មបថ បើពោលដោយសង្ខេបមាន១០ បើពោលដោយពិស្តារមាន៤០។

### ក- កុសលកម្មបថ១០

កុសលកម្មបថ១០នេះ ចែកជា កាយកម្មមាន៣ វចីកម្មមាន៤ មនោកម្មមាន៣។

**កាយកម្ម ៣យ៉ាង:**

**១-បាណាតិបាតា វេរមណី :** ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ។

**២-អទិន្នាទានា វេរមណី :** ចេតនា ជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា។

**៣-កាមេសុមិច្ឆាចារា វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

## វចីកម្ម ៤យ៉ាង

**១-មុសាវាទា វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

**២-បិសុណាយ វាចាយ វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់ ស៊កសៀត បំបែកបំបាក់អ្នកដទៃ។

**៣-ផរុសាយ វាចាយ វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម។

**៤-សម្ផប្បលាបា វេរមណី** : ចេតនា ជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយ ឥតប្រយោជន៍។

## មនោកម្ម ៣យ៉ាង

**១-អនភិជ្ឈា** : មិនមានចិត្តគិតសម្លឹងរំពៃ ចំពោះទ្រព្យរបស់អ្នកដទៃដោយគិតបម្រុងនឹងឱ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ។

**២-អព្យាបាទោ :** មិនមានចិត្តចងគំនុំគុំកួនគិតបម្រុងនឹងឱ្យអ្នកដទៃដល់នូវសេចក្តីវិនាសឡើយ។

**៣-សម្មាទិដ្ឋិ :** គំនិតយល់ឃើញពិត ហើយប្រកាន់ឡើងថា ត្រូវមែន។

## ខ-កុសលកម្មបថពិស្តារ

កុសលកម្មបថពិស្តារមាន៤០ គឺកាយកម្មមាន១២ វចីកម្មមាន១៦ និងមនោកម្មមាន១២។

កុសលកម្មបថ៤០នេះ មានលក្ខណៈផ្ទុយគ្នាពីអកុសលកម្មបថ៤០។ រីឯអកុសលកម្មបថ៤០នោះ បានពោលហើយខាងលើ សូមបណ្ឌិតគប្បីពិចារណាតាមដំណើរនេះចុះ។

## ១០-សេចក្តីសង្រួមក្នុងឥន្រ្ទិយទាំង៦

សាធុជនដែលបានសង្រួមតាមសិក្ខាបទ១០ លះបង់មិនប្រព្រឹត្តធ្វើតាមអកុសលកម្មបថ១០ ឬ ៤០ ប្រព្រឹត្តសង្រួមតាមតែកុសលកម្មបថ១០ ឬ៤០ សីលទាំង១០នេះ ដែលអាចស្ថិតនៅដ៏បរិសុទ្ធបាន អ្នករក្សាសីលនោះគប្បីសង្រួមនូវឥន្រ្ទិយទាំង៦ ឱ្យបានហ្មត់ហ្មង។ កាលបើឃើញរូបដោយភ្នែក ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ស្រង់ស្រូបរសដោយអណ្តាតប៉ះពាល់នូវនិមិត្ត និងអនុព្យញ្ជនៈក្នុងអារម្មណ៍ទាំងនោះ

ខំតែប្រតិបត្តិរក្សានូវឥន្ទ្រិយទាំង៦ មិនឱ្យអកុសលធម៌លាមកមាន អភិជ្ឈា និងទោមនស្សជាដើម គ្របសង្កត់ចិត្តបានប៉ុណ្ណោះ ហៅថាសេចក្តីសង្រួមក្នុងឥន្ទ្រិយ ។

## ១១.សេចក្តីអត្ថាធិប្បាយរបស់សេចក្តីសង្រួម

ត្រង់ពាក្យថា មិនបានកាន់យកនូវនិមិត្តនិងអនុព្យញ្ជនៈមានសេចក្តីថាៈ ហេតុដែលអាស្រ័យនៅក្នុងសន្តានរបស់ស្ត្រីហៅថា ឥត្ថីនិមិត្ត។ ដែលអាស្រ័យនៅក្នុងសន្តានរបស់បុរសហៅថាបុរិសនិមិត្តឬយ៉ាងទម្រង់រូបដែលប្លែកគ្នា ភាពដែលមានសាច់ដោះដុះខ្លោតឡើង និង មិនខ្លោតឡើង ភាពដែលមិនមានពុកមាត់ ពុកចង្កា និងមានពុកមាត់ ពុកចង្កាមានសំពត់សម្រាប់ចងសក់ និងមិនមានសំពត់សម្រាប់ចងសក់ជាដើម ។ ពុំនោះហេតុជាទីកើតនៃកិលេស ក៏ហៅថានិមិត្តដែរ គឺហេតុជាទីកើតនៃរាគៈហៅថាសុភនិមិត្ត[៧] ដែលជាទីកើតនៃទោសៈហៅថាបដិឃនិមិត្ត[៨] ដែលជាទី

---

[៧] : អាការជាទីប្រាថ្នា ដែលជាហេតុឱ្យកើតរាគៈ ។

[៨] : អាការមិនជាទីប្រាថ្នាដែលជាហេតុនាំឱ្យកើតទោសៈ ។

កើតនៃមោហៈ ហៅថា ឧបេក្ខានិមិត្ត[៩]។ អាការ មានដៃ ជើង ក្បាល សំណើច សម្តីនិយាយ សម្តីវាចា ទៅមក និងអាការ ក្រឡេកចុងភ្នែក ដើមភ្នែកជាដើមរបស់ស្ត្រី និងបុរស ដែលជាគ្រឿងធ្វើនូវភាពរបស់កិលេស ឱ្យប្រាកដឡើង ហៅថា អនុព្យញ្ជនៈ។ ត្រង់ដែលថា មិនកាន់យកសោះ គឺមិនសម្គាល់ថា "នេះស្ត្រី នេះប្រុស នេះស្អាត នេះមិនស្អាត នេះពីរោះ នេះមិនពីរោះ " ដូច្នេះជាដើម គឺឱ្យនៅតែត្រឹមឃើញត្រឹមឮប៉ុណ្ណោះ ឬអាការណាដែលមាននៅក្នុងសរីរៈដូចសក់ និងរោមជាដើមក៏សម្គាល់ថា "នេះសក់នេះរោម" ជាដើមប៉ុណ្ណោះឯង។ ឯអារម្មណ៍ដទៃទៀតដែលមក ប៉ះពាល់ដល់ទ្វារផ្សេងទៀត ក្រៅពីនេះក៏គប្បីត្រិះរិះយកតាមលំអានដែល ពោលមកនេះផងចុះ។ ត្រង់ពោលថា ខំប្រតិបត្តិរក្សានូវឥន្ទ្រិយទាំង៦នោះ មានសេចក្តីថាៈ ត្រូវប្រុងប្រយត្ន័ ស្មារតី យកស្មារតីជាសន្ទះសម្រាប់ បិទនូវទ្វារទាំង៦ មានចក្ខុទ្វារជាដើម ការពារមិនឱ្យអារម្មណ៍ដែលជា គ្រឿងសត្រូវ គួរឱ្យកើតសេចក្តីស្អប់ ស្រឡាញ់ចូលទៅលុកលុយក្នុង ហទយវត្ថុបាន កាលបើមានអារម្មណ៍ ទាំងនោះមកប៉ះពាល់ត្រូវយក

---

[៩] : អារម្មណ៍ដែលជាវត្ថុនៃអញ្ញាណុបេក្ខា។

ស្មារតីទប់ឱ្យនៅទើត្រឹមតែទ្វារប៉ុណ្ណោះ គឺ ថាមិនត្រូវភ្លេចស្មារតីបណ្តោយចិត្តឱ្យលង់ឈ្លក់ទៅក្នុងអារម្មណ៍ទាំងនោះដោយស្ថានណានីមួយៗឡើយ។

សាធុជនអ្នករក្សានូវសីល១០ កាលបើធ្វើនូវសេចក្តីសង្រួមក្នុងឥន្ទ្រិយទាំង៦ហើយ ប្រសិនណាបើមិនបានពិនិត្យទៅលើអាចារៈ(ការប្រព្រឹត្តដោយកាយឬវាចា) និងគោចរៈ(ការត្រាច់ទៅកាន់ស្ថានផ្សេងៗ) ឱ្យបានសមរម្យទេនោះ មុខជានឹងមិនអាចសង្រួមក្នុងឥន្ទ្រិយទាំង៦បានឡើយ ព្រោះរវល់តែជួបនឹងវិសភាគារម្មណ៍(អារម្មណ៍មិនស្មើ)។

## ក- <u>**អាចារៈ និងអនាចារៈ**</u>

### <u>**អាចារៈ**</u>

មារយាទ ឬ សណ្តាប់ ដែលត្រូវការដោយប្រយោជន៍ទាំងឡាយសូមនិយាយពីអាចារជាដំបូងសិន ព្រោះធម៌ទាំងពីរជាគូបដិបក្ខនឹងគ្នា គឺ អាចារ១ និងអនាចារ១។ អាចារ ប៉ែកខាងកុសល អានាចារ ប៉ែកខាងអកុសល។

អានាចារ នេះលោកសំដៅយកសេចក្តីប្រព្រឹត្តល្មើសដោយកាយ ឬដោយវាចា ឬដល់ព្រមទាំងកាយទាំងវាចា។ន័យ១ទៀតថាៈ សំដៅយកភាពដែលទ្រុស្តសីលទាំងអស់។ តែបើពោលពីការចិញ្ចឹមជីវិតវិញ សំដៅយក

មិច្ឆាជីវៈ(ការចិញ្ចឹមជីវិតខុស) មានជួញសស្ត្រាវុធ មនុស្ស ចិញ្ចឹមសត្វសម្រាប់កាប់សាច់លក់ ទឹកស្រវឹង ថ្នាំពិស ឬ ក៏របររកស៊ីណាដែលជាប់ពាក់ពន្ធ័ដោយសីល និងវត្តក្នុងសាសនាដទៃ មានធ្វើគ្រូហ្ម ស្រោចទឹកចងខ្សែគាថា គូរយន្ត ស្តោះព្រួស ឬ ក៏វិធីការផ្សេងៗក្រៅចាកព្រះពុទ្ធសាសនា ដើម្បីយកលាភសក្ការៈមកចិញ្ចឹមជីវិត។ ពុំនោះសោតសម្តែងអាការបន្ទាបខ្លួន អែបអបការពារពាក្យភ្លាត់របស់អ្នកដទៃ ឬ ធ្វើជាសាក្សីកោង ដើម្បីឱ្យគេស្រឡាញ់ខ្លួន ឬ ក៏ពោលពាក្យឡេះឡោះ ពិតខ្លះ ទេខ្លះ ដូចជាសម្លសណ្តែកបាយ ឆ្អិនខ្លះឆៅខ្លះ ឬ ក៏ឃុបឃិតនឹងឈ្មួញ ដែលរកស៊ីខុសច្បាប់មានជួញគ្រឿងញៀន ឬ ក៏ជួយបិទបាំងនូវជនដែលប្រព្រឹត្តខុសច្បាប់ ដើម្បីបានកម្រៃសម្រាប់ចិញ្ចឹមជីវិតជាដើម លោកហៅថាអនាចារទាំងអស់។ អ្នករក្សាសីល១០ ត្រូវជៀសវាងនូវអំពើជាអនាចារដូចបានពោលខាងលើ ហើយត្រូវប្រព្រឹត្តនូវអភិសមាចារ (ប្រព្រឹត្តស្មើល្អប្រពៃតាមធម៌វិន័យ)។

ខ- **<u>អភិសមាចារមាន២</u>**

**១-កាយាភិសមាចារ :** ប្រព្រឹត្តស្មើល្អប្រពៃដោយកាយ[១០]។

**២-វាចាភិសមាចារ :** ប្រព្រឹត្តស្មើល្អប្រពៃដោយវាចា[១១]។

---

[១០, ១១] : អនុវត្តតាមវិន័យរបស់គ្រហស្ថ មានប្រព្រឹត្តតាមសម្មាជីវៈជាដើម។

# ១២_គោចរៈ និងអគោចរៈ

សភាពដែលជាកន្លែងជាទីត្រាច់ទៅរបស់ឥន្ទ្រិយទាំង៦ មាន : ចក្ខុ-ន្ទ្រិយជាដើម ។ បើពោលឱ្យអស់ជើងទៅ មានទាំងអាក្រក់ទាំងល្អ គឺ អារម្មណ៍ដែលជាហេតុឱ្យកើតទោស មានទ្រុស្តសីលជាដើមក៏មាន ជាហេតុឱ្យកើតគុណមានសីលគុណក៏មាន ។ តែក្នុងទីនេះ លោកសំដៅយក តែអារម្មណ៍ជាហេតុឱ្យកើតគុណ មានសីលគុណជាដើមតែម្យ៉ាងប៉ុណ្ណោះ ។ ឯអារម្មណ៍ដែលជាហេតុឱ្យកើតទោស មានទ្រុស្តសីលជាដើមនោះ លោកមិនសំដៅយកឡើយ គឺលោកឱ្យឈ្មោះថា "អគោចរ" ដូច្នេះវិញ ព្រោះហេតុនេះ ដែលនឹងអាចពន្យល់ឱ្យងាយចូលចិត្តអំពីគោចរនេះបាន តោងតែអធិប្បាយអំពីអគោចរទុកជាមុនសិន ។

អារម្មណ៍ដែលជាអគោចរនោះ បើពោលជាបុគ្គលាធិដ្ឋានសំដៅយកកន្លែងស្ត្រីពេស្យា រោងសុរា ជាដើម ។ ន័យមួយទៀត គោចរលោកចែកជាបីគឺ

**១-ឧបនិស្សយគោចរ** : អារម្មណ៍ជាឧបនិស្ស័យនៃសីលគុណជាដើម បាន ដល់កល្យាណមិត្ត ។

**២-អារក្ខគោចរ** : អារម្មណ៍ជាគ្រឿងរក្សាទុកនូវចក្ខុទ្វារជាដើម បានដល់ សតិ ។

**៧-ឧបនិពន្ធគោចរ** : អារម្មណ៍ជាគ្រឿងចងទុកនូវចិត្ត បានដល់សតិបដ្ឋាន[១២] ។

## សេចក្តីអធិប្បាយគោចរៈ និងអគោចរៈ

លោកដែលជាកល្យាណមិត្តបរិបូរដោយគុណ គឺកថាវត្ថុ១០[១៣] ក្តីលោកដែលជាពហុស្សូត តែងណែនាំអ្នកដែលចូលទៅនៅជ្រកកោនអាស្រ័យឱ្យបានស្តាប់នូវធម៌ដែលមិនទាន់បានស្តាប់ ដែលបានស្តាប់ហើយឱ្យកាន់តែផូរផង់ឡើង ឱ្យឆ្លងផុតចាកសេចក្តីសង្ស័យក្នុងធម៌ដែលគួរឱ្យសង្ស័យ ឱ្យបានតម្រង់សេចក្តីយល់ឱ្យត្រង់ ឱ្យបានញុំាងចិត្តរបស់ខ្លួនឱ្យជ្រះថ្លាឡើងក្តី លោកដែលបរិបូរដោយ **សទ្ធា សីល សុត ចាគ បញ្ញា** កាលបើបានបុគ្គលណាមួយ

---

[១២] : ក្នុងទីនេះ លោកពោលថាបានដល់កម្មដ្ឋាន ។

[១៣] : កថាវត្ថុ១០ គឺអប្បិច្ឆកថា ពាក្យនាំឱ្យមានសេចក្តីប្រាថ្នាតិច១ សន្តុដ្ឋិកថា ពាក្យនាំឱ្យមានសេចក្តីសន្តោស១ បវិវេកកថា ពាក្យនាំឱ្យមានសេចក្តីស្ងប់ស្ងាត់១ អសំសគ្គកថា ពាក្យនាំមិនឱ្យជាប់ជំពាក់១ វីរិយារម្ភកថា ពាក្យនាំប្រារព្ធព្យាយាម ១ សីលកថា ពាក្យនាំឱ្យតាំងនៅក្នុងសីល១ សមាធិកថាពាក្យនាំឱ្យសមាធិកើត១ បញ្ញាកថា ពាក្យនាំឱ្យបញ្ញាកើត១ វិមុត្តិកថា ពាក្យនាំឱ្យវិមុត្តិកើតឡើង១ វិមុត្តិញាណទស្សនកថា ពាក្យនាំឱ្យវិមុត្តិញាណទស្សនកើត១ ។

សិក្សាតាមទៅហើយ មុខជានឹងបានចម្រើនដោយគុណទាំងនោះក្តី លោកទាំងនេះចាត់ជាឧបនិស្ស័យគោចរដោយបុគ្គលាធិដ្ឋានទេសនា។

អារក្ខគោចរសោត ក៏ព្រះសក្យមុនីទ្រង់ត្រាស់សម្តែងទុកបុគ្គលាធិដ្ឋានទេសនាដូចគ្នា ថាភិក្ខុក្នុងសាសនានេះ វេលាចូលទៅកាន់ស្រុកក្តី ដើរទៅតាមថ្នល់ក្តី តែងមានចក្ខុសម្លឹងចុះក្រោម ក្រឡេកមើលប្រមាណមួយជួរនឹម ដើរសង្រួមប្រយ័ត្នដោយល្អ មិនបានក្រឡេកមើល ដំរី សេះ រថ អ្នកថ្មើរជើង ស្រីប្រុសជាដើម មិនមើលទៅលើ មិនអើតឈ្ងោកមើលទៅក្រោម មិនក្រឡេកមើលទៅក្រោម មិនក្រឡេកមើលទៅទិសផ្សេងៗ ទាំងនេះចាត់ជាអារក្ខគោចរ។

ឯឧបនិពន្ធគោចរ សំដៅយកសតិបដ្ឋានទាំង៤ ដោយត្រង់ៗ ព្រោះសតិបដ្ឋានទាំង៤នោះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ទុកថាជាអារម្មណ៍ដែលព្រះអង្គជាបិតាទ្រង់ប្រទានទុកឱ្យសម្រាប់ចងក្រៀកទុកនូវភាវនាចិត្តសមដូចជាគាថា ដែលលោកនិពន្ធទុកដូច្នេះ : **យថាថម្ភេ និពន្ធេយ្យ វច្ឆំ ទមន្នរោ ឥធ ពន្ធេយ្យេវំ សកំ ចិត្តំ សតិយារម្មណេ ទឡ្ហំ ។**

សេចក្តីថា : នរជនក្នុងលោកនេះ កាលដែលទូន្មាននូវកូនគោ គេរមែងចងក្រៀកទុកនឹងសសរស្តម្ភឱ្យយ៉ាងមាំដូចម្តេចមិញ ឯព្រះយោគាវចរកុលបុត្ត

សោត កាលទូន្មាននូវចិត្តរបស់ខ្លួន ក៏ត្រូវតែចងក្រៀកនូវចិត្តនោះដោយសតិយ៉ាងមាំក្នុងអារម្មណ៍របស់សតិបដ្ឋានដូច្នោះ ទើបអាចដើម្បីនឹងទូន្មានបាន ទាំងនេះចាត់ជាឧបនិពន្ធគោចរ ។

សីលវន្ត-សីលវតី[១៤] ដែលប្រព្រឹត្តនូវអភិសមាចារនិងគោចរឱ្យបានត្រឹមត្រូវយ៉ាងនេះ មិនមែនដើម្បីប្រយោជន៍អ្វីដទៃទៀយ ដើម្បីនឹងបិទទុកនូវឥន្ទ្រិយទាំងនោះកុំឱ្យអកុសលធម៌ទាំងពួងក្នុងសន្តានប៉ុណ្ណោះ ព្រោះថាអកុសលធម៌ទាំងនេះ តែបណ្តោយឱ្យចូលទៅដល់ក្នុងសន្តានបានហើយ មុខជានឹងបំផ្លាញនូវកុសលធម៌ទាំងពួងមិនឱ្យមានសេសសល់ឡើយ ហាក់ដូចជាបណ្តោយឱ្យចោរចូលស្រុកដូច្នោះឯង ។

## ១៣. សង្រួម និងមិនសង្រួម

ក្នុងឥន្ទ្រិយសំវរសីលនេះ មានគ្រឿងកំណត់ថាសង្រួម ឬមិនសង្រួមដោយអំណាចនៃសំវរធម៌ និងអសំវរធម៌ណា១កើតឡើង ។ កាលបើធម៌ទាំងនេះមិនទាន់កើតឡើងទេ នឹងហៅថាសង្រួម ឬ មិនសង្រួមក៏មិនទាន់បានឡើយ ។ ធម៌ដែលសម្រាប់កំណត់ឱ្យដឹងថា សង្រួមហៅថា "អសំវរធម៌" ហើយក្នុងធម៌នីមួយៗចែកចេញទៅទៀតមានប្រាំៗដូចគ្នា ។

---

[១៤] :សីលវន្ត( បុរសអ្នកកាន់សីល ១០) ។ សីលវតី ស្ត្រីអ្នកកាន់សីល ១០ ។

## ក- **សំវរធម៌៥ គឺ**

**១-សីលសំវរៈ** : ធម៌សង្រួម គឺសីល

**២-សតិសំវរៈ** : ធម៌សង្រួម គឺស្មារតី

**៣-ញាណសំវរៈ** : ធម៌សង្រួម គឺបញ្ញា

**៤-ខន្តិសំវរៈ** : ធម៌សង្រួម គឺសេចក្តីអត់ធន់

**៥-វិរិយសំវរៈ** : ធម៌សង្រួម គឺព្យាយាម

## ខ- **អសំវរធម៌ មាន៥ គឺ**

**១-ទុស្សីល** : ភាព ជាអ្នកទ្រុស្តសីល

**២-មុដ្ឋសច្ច** : ភាព ជាអ្នកភ្លេចស្មារតី

**៣-អញ្ញាណ** : សេចក្តីមិនដឹង

**៤-អក្ខន្តិ** : សេចក្តីមិនអត់ទ្រាំ

**៥-កោសជ្ជៈ** : សេចក្តីខ្ជិលច្រអូស

## គ- **សេចក្តីអធិប្បាយអំពីសំវរធម៌ និងអសំវរធម៌**

កាលបើអារម្មណ៍ទាំង៦ អារម្មណ៍ណាមួយមកប៉ះពាល់ដល់ទ្វារទាំង៦មានចក្ខុទ្វារជាដើម ទ្វារណាមួយ ហើយបណ្តាលឱ្យអស់សំវរធម៌ទាំង៥

យ៉ាងកើតឡើង សូម្បីតែធមិណាមួយក្តី ក៏ត្រូវដឹងបានថា ទ្វារនោះភិក្ខុមិនបានសង្រួមបិទដោយល្អទេ ព្រោះថា សេចក្តីសង្រួមនិងមិនសង្រួមនោះមិនមែនកើតតែត្រឹមទ្វារមានចក្ខុទ្វារជាដើមនោះឡើយ ។

ចុះបើសេចក្តីសង្រួមនិងមិនសង្រួមមិនមែនកើតត្រឹមតែចក្ខុទ្វារជាដើមទេ តើកើតដល់ទៅត្រឹមណាវិញ?

ដំណើរនេះ ត្រូវដឹងតាមលំដាប់នៃវិថីចិត្តដូចពោលតទៅនេះ តែនឹងពោលតែក្នុងចក្ខុទ្វារមួយប៉ុណ្ណោះ គ្រាន់ជាតួយ៉ាង ។ ក៏ក្នុងចក្ខុទ្វារនេះកាលបើរូបារម្មណ៏មកប៉ះពាល់ដល់រង្វង់នៃចក្ខុបសាទហើយ ភវង្គក៏កើតឡើងហើយរលត់ទៅអស់វារៈ២ដងទៅតាមលំដាប់ កិរិយាមនោធាតុដែលជាតួចក្ខុទ្វារាវជ្ជនចិត្ត ញ៉ាំងអាវជ្ជនកិច្ច គឺកិច្ចដែលពិចារណាវារករូបារម្មណ៏នោះឱ្យសម្រេចកើតឡើង១ខណៈ ទើបរលត់ទៅ បន្ទាប់មកចក្ខុវិញ្ញាណញ៉ាំងទស្សនកិច្ច គឺកិច្ចដែលឃើញនូវរូបារម្មណ៏នោះឱ្យសម្រេចកើតឡើង១ ខណៈរលត់ទៅ បន្ទាប់មកវិបាកមនោធាតុដែលជាតួសម្បដិច្ឆន្នចិត្តញ៉ាំងសម្បដិច្ឆន្នកិច្ច គឺកិច្ចដែលទទួលរងនូវរូបារម្មណ៏នោះឱ្យសម្រេចកើតឡើង១ខណៈរលត់ទៅ ទើបវិបាកាហេតុកមនោវិញ្ញាណធាតុ ដែលជាតួសន្តីរណចិត្ត ញ៉ាំងសន្តីរណកិច្ច គឺកិច្ចដែលត្រិះរិះឈ្លេចឈ្លី

នូវរូបារម្មណ៍នោះឱ្យសម្រេចកើតឡើង១ ខណៈរលត់ទៅ ត មកកិរិយាហេតុកមនោវិញ្ញាណធាតុ ដែលជាតួវោដ្ឋព្វនចិត្ត ញ៉ាំងវោដ្ឋព្វនកិច្ច គឺកិច្ចដែលកត់ត្រាទុកនូវរូបារម្មណ៍ឱ្យសម្រេចកើតឡើង១ខណៈរលត់ទៅ ខាងក្រោយបំផុត ទើបជវនៈប្រព្រឹត្តទៅតាមភាពរបស់អារម្មណ៍ដែលគួរឱ្យកើតសំវរធម៌ ឬ អសំវរធម៌ ដូចបានពោលមកហើយ ។

ក្នុងសម័យនៃភវង្គជាដើមនោះ មិនទាន់បានឈ្មោះថា សង្រួម ឬ មិនសង្រួមនៅឡើយទេ ដែលបានឈ្មោះថា សង្រួម ឬ មិនសង្រួមគ្រាក្នុងសម័យរបស់ជវនៈ ព្រោះសំវរធម៌ទាំង៥ក្តី អសំវរធម៌ទាំង៥ក្តី ដែលនឹងកើតឡើង ក៏កើតក្នុងខណៈរបស់ជវនៈតែម្យ៉ាង ។ ហេតុនោះកាលបើអារម្មណ៍ណាមួយចូលមកតាមទ្វារមានទ្វារចក្ខុជាដើមបណ្តាលឱ្យវិថីចិត្តកើតរៀងតាមលំដាប់ដរាបដល់ជវនវិថីជាទីបំផុត ហើយសំវរធម៌ ឬ អសំវរធម៌ណាមួយកើតឡើង ទើបអាច នឹងឱ្យឈ្មោះថា "សង្រួម ឬ មិនសង្រួម" ។ ក៏ប្រសិនបើធម៌ គឺទុស្សីលក្តី មុដ្ឋសច្ចៈក្តី អញ្ញាណក្តី អក្ខន្តិក្តី កោសជ្ជក្តី កើតឡើងក្នុងខណៈនៃជវនៈហើយ អសំវរធម៌មានមានកាលយ៉ាងនេះអសំវរៈនោះលោកហៅថា "អសំវរធម៌ក្នុងចក្ខុន្ទ្រិយ" ។ ពីព្រោះអ្វី? ព្រោះថាអសំវរធម៌នោះកាលកើតឡើងបាន ដោយហេតុតែ

សីលវន្ត-សីលវតីមិនបានគ្រប់គ្រងរក្សានូវទ្វារផង ភវង្គផង វិថីចិត្ត មានអាវជ្ជនចិត្តជាដើមផង ។តើមានសេចក្តីប្រៀបធៀបជាអ្វី? ចូរពោល

កាលដែលទ្វារក្នុងនគរទាំង៤ គឺគេមិនបានបិទល្អហើយនោះ រឹង របស់ទាំងឡាយមានទ្វារនៃផ្ទះនិងទ្វារនៃឃ្លាំងព្វដ៏ខាងក្នុងជាដើម ដែល គេបានបិទល្អក៏ពិតមែនហើយ ក៏ឈ្មោះថា ភណ្ឌៈទាំងអស់ព្វដ៏ខាងក្នុង នគរជាវត្ថុគឺគេមិនរក្សាដោយពិត ។ ព្រោះថាចោរទាំងឡាយអាចចូលទ្វារ នគរនោះ បើប្រាថ្នាយកនូវវត្ថុណា គប្បីកាន់យកនូវវត្ថុនោះបាន មាន ឧបមាយ៉ាងណា អសំវរធម៌មានទុស្សីលជាដើម កើតឡើងហើយក្នុង ជវនៈ កាលដែលអសំវរធម៌ កាលមានយ៉ាងនេះ ទ្វារផង ភវង្គផង វិថីចិត្ត មានអាវជ្ជនៈជាដើមផង ក៏ឈ្មោះថាភិក្ខុនោះមិនបានគ្រប់គ្រងហើយដែរ ក៏មានសេចក្តីឧបមេយ្យ ក៏យ៉ាងនោះ ។

ន័យមួយទៀត កាលដែលទ្វារនគរទាំងអស់ គឺគេបានបិទជិតល្អ ហើយ ចំណែកឯរបស់ទាំងឡាយ ផ្ទះព្វដ៏ខាងក្នុងដែលគេមិនបានបិទបាំង ការពារល្អទេ ក៏ឈ្មោះថាភណ្ឌទាំងអស់ខាងក្នុងនគរគឺគេបានរក្សាគ្រប់ គ្រងល្អហើយ ចោរទាំងឡាយមិនអាចចូលទៅលួចយកភណ្ឌៈទាំងនោះបាន មានសេចក្តីឧបមាយ៉ាងណា កាលដែលសំវរធម៌មានសីលជាដើមកើតឡើង

ត្រង់ជវនចិត្តហើយ  វីទ្វារមានចក្ខុទ្វារជាដើមផង  ភវង្គផង  វិថីចិត្តមាន អាវជ្ជនជាដើមផង  ជាធម្មជាតិគឺភិក្ខុគ្រប់គ្រងល្អ  ហើយក៏មានសេចក្ដី ឧបមេយ្យក៏យ៉ាងនោះ។ ការពោលមកហើយនេះ  គឺ  ជាការពោលអំពី សំវរធម៌  និងអសំវរធម៌  ដែលកើតតាមចក្ខុទ្វារប៉ុណ្ណោះ  រីឯសំវរធម៌ ដែលកើតតាមទ្វារឯទៀត  មានសោតទ្វារជាដើម  សូមអ្នកសិក្សាគប្បី យល់តាមដំណើរនៃការកើតឡើងនៃសំវរធម៌  និងអសំវរធម៌តាមចក្ខុ ទ្វារនេះផងចុះ។ ក៏ឥន្ទ្រិយសំវរ សីលវន្ត សីលវតីគប្បីឱ្យសម្រេចដោយ សតិ គឺមានសតិជាជំនួយឱ្យសម្រេច ព្រោះថាឥន្ទ្រិយទាំង៦បើសីលវន្ត-សីលវតីតាំងទុកដោយសតិហើយ អសំវរធម៌ទាំងឡាយមានអភិជ្ឈាជាដើម មិនគប្បីតាមជិះជាន់បានឡើយ។

មានសេចក្ដីសរសើរថា : ឥន្ទ្រិយសំវរៈនេះ កាលបើបានសម្រេច ដោយល្អហើយនិងបានជាជំនួយដល់សីល១០ផងទៀត គឺថាអាចនឹងញ៉ាំង សីល១០ នោះឱ្យតាំងនៅខ្ជាប់ខ្ជួនអស់កាលយូរ ហាក់ដូចជាសន្ទូងដែលគេ បិទបាំងល្អដោយរបង។ មិនត្រឹមតែប៉ុណ្ណោះ សីលវន្ត-សីលវតីរូបនោះ គឺ ចោរ ពោលគឺកិលេសមិនអាចចូលមកបៀតបៀនបាន ហាក់ដូចជាស្រុក ដែលគេបានបិទទ្វារជិតដោយល្អហើយ  មិនមានឱកាសល្មមឱ្យចោរចូល

ទៅរើបជាន់បានឡើយ ។ សមដូចជាគាថា ដែលលោកពោលទុកដូច្នេះ

**"រូបេសុ សទ្ទេសុ អថោ រសេសុ គន្ធេសុ ផស្សេសុ ច រក្ខតិន្ទ្រិយំ ឯតេ ហិ ទ្វារា បិទហិតា សុសំវុតា ន ហនន្តិ គាមំវ បរស្ស ហារិនោ "**

សេចក្ដីថា : បុគ្គលត្រូវតែរក្សាទុកនូវឥន្ទ្រិយការពារកុំឱ្យអន្តរាយកើតឡើង ព្រោះតែរូប សំឡេង ក្លិន រស និងផ្សព្វទាំងឡាយ ព្រោះថាទ្វារទាំងឡាយមានចក្ខុទ្វារជាដើម តែបុគ្គលណាបិទបាំងល្អហើយ នឹងបៀតបៀននូវបុគ្គលនោះវិញមិនបាន ហាក់ដូចជាស្រុកដែលគេបានបិទទ្វារជិតល្អហើយ ចោរទាំងឡាយក៏មិនអាចដើម្បីនឹងបៀតបៀននូវអ្នកស្រុកបានឡើយ ។ ន័យមួយទៀត ឥន្ទ្រិយសំវរសីលនេះ បើសីលវន្ត-សីលវតីអង្គនោះ បានធ្វើឱ្យសម្រេចហើយ រាគៈក៏មិនអាចចាក់ទម្លុះចិត្តរបស់សីលវន្ត-សីលវតីអង្គនោះបានឡើយ ហាក់ដូចជាតំណក់ទឹកភ្លៀងដែលមិនអាចនឹងលិចស្រោចនូវផ្ទះដែលគេប្រក់យ៉ាងជិតល្អក៏យ៉ាងនោះឯង ។ មានគាថាដែលព្រះពុទ្ធដ៏មានព្រះភាគទ្រង់ត្រាស់ទុកជាគ្រឿងពិសោធន៍ដូច្នេះ

**យថា អគារំ សុច្ឆន្នំ វុដ្ឋិ ន សមតិវិជ្ឈតិ ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ។**

សេចក្តីថា តំណក់ទឹកភ្លៀងមិនអាចលិចស្រោចនូវផ្ទះដែលគេប្រក់ជិតដោយល្អយ៉ាងណា រាគៈក៏មិនអាចនឹងចាក់ទម្លុះនូវចិត្តដែលបុគ្គលបានចម្រើនដោយល្អដូច្នោះឯង។

## ១៤~ឃើញភ័យក្នុងទោសបន្តិចបន្តួច

សេចក្តីថា ក្នុងសិក្ខាបទទាំង១០ ឬ កម្មបថ២០ ឬក៏៨០ ដែលជាអចិត្តកសិក្ខាបទ(សិក្ខាបទដែលគ្មានចិត្តក្លែង ឬ ធ្វើឱ្យខុស) មានសិក្ខាបទសុរាមេរ័យ ឬ ក៏សិក្ខាបទ វិកាលភោជនាជាដើម សូម្បីបុគ្គលប្រព្រឹត្តកន្លងដោយមិនមានចិត្តក្លែងក៏គង់ដាច់សីលដែរ។ អកុសលចិត្តទាំង១២ មានលោកមូល៨ ជាដើមកើតឡើងក្នុងចិត្តទាំងនេះ លោកហៅថាទោសបន្តិចបន្តួច។

សីលវន្ត-សីលវតី ទាំងឡាយគប្បីរំពឹងពិចារណាឱ្យបានច្រើននូវអំពើឬក៏អកុសលចិត្ត ដែលកើតឡើងក្នុងខន្ធសន្តានដូចបានពោលហើយខាងលើ ដើម្បីញ៉ាំងចិត្តឱ្យឃើញភ័យក្នុងកំហុស សូម្បីទោសបន្តិចបន្តួចជាការប្រពៃណាស់ ព្រោះនាំចិត្តឱ្យចុះកាន់វិវេកហើយដល់នូវសេចក្តីស្ងប់ស្ងាត់។

## ១៥.លះបង់នូវមិច្ឆាជីវៈ សមាទានកាន់យកសម្មាជីវៈ

ពាក្យថាមិច្ឆាជីវៈ មានន័យថាការចិញ្ចឹមជីវិតខុស។ សីលវន្ត-សីលវតីទាំងឡាយអ្នកប្រតិបត្តិធម៌ដើម្បីឱ្យជាក់ច្បាស់នូវព្រះនិព្វានដោយប្រាជ្ញានៃខ្លួន គប្បីជម្រះនូវការចិញ្ចឹមជីវិតឱ្យសមប្រកបតាមវិន័យក្នុងព្រះពុទ្ធសាសនា។ មិច្ឆាជីវៈនោះមានច្រើនប្រការ តែក្នុងទីនេះសុំលើកតែ២ប្រការ មកពោលប៉ុណ្ណោះ។

**ប្រការ១: មច្ឆាជីវៈ ៥យ៉ាង**

**១-សត្ថវណិជ្ជា** : ជួញគ្រឿងសស្ត្រាវុធសម្រាប់ប្រហារគឺធ្វើគ្រឿងសស្ត្រាវុធនោះដោយខ្លួនឯង ឬប្រើអ្នកដទៃធ្វើឱ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវគ្រឿងសស្ត្រាវុធនោះ។

**២-សត្តវណិជ្ជា** : ជួញមនុស្ស។

**៣-មំសវណិជ្ជា** : ជួញសាច់ គឺចិញ្ចឹមនូវសត្វទាំងឡាយមានជ្រូកជាដើមលុះដល់សត្វទាំងឡាយចម្រើនធំឡើង ក៏សម្លាប់យកសាច់លក់។

**៤-មជ្ជវណិជ្ជា** : ជួញទឹកស្រវឹង គឺផ្សំគ្រឿងណាមួយឱ្យកើតឡើងជាទឹកស្រវឹងដោយខ្លួនឯង ឬ ទិញគេយកមក ហើយលក់នូវទឹកស្រវឹងនោះ។

**៥-វិសវណិជ្ជា** : ជួញថ្នាំពិស គឺចាត់ចែងផ្សំថ្នាំពិសឱ្យកើតឡើង ដោយខ្លួនឯង ឬឱ្យគេផ្សំឱ្យ ឬ បានមកដោយហេតុឯណាមួយហើយលក់នូវថ្នាំពិសនោះ ។

សីលវន្ត-សីលវតី កាលវៀរចាកជំនួញខុសទាំង៥ប្រការនេះហើយ បានប្រព្រឹត្តការចិញ្ចឹមជីវិតដោយធម៌ ឈ្មោះថាមានសម្មាជីវៈដោយប្រពៃ ។

**ប្រការ២ : តិរច្ឆានវិជ្ជា**

តិរច្ឆានវិជ្ជាគឺចំណេះដ៏ថោកទាប ទុកដូចជាចំណេះរបស់សត្វតិរច្ឆាន ព្រោះមិនមានប្រយោជន៍ ។ តិរច្ឆានវិជ្ជានោះមានច្រើនជាអនេក តែក្នុងទីនេះសូមស្រង់យកតែតិរច្ឆានវិជ្ជា១ចំនួនប៉ុណ្ណោះដែលមានទំនាស់ដល់ត្រៃសរណគមន៍និងសីលរបស់សីលវន្ត-សីលវតីមកពោលទុកដោយសេចក្តីសង្ខេប ។

## តិរច្ឆានវិជ្ជា៨

**១-អង្គំ** : តម្រានិយាយអំពីសរីរាវយវៈមានដៃ និងជើង ជាដើម ។

**២-និមិត្តំ** : តម្រាសម្រាប់ទាយនូវហេតុផ្សេងៗ ។

**៣-ឧប្បាតំ** : តម្រានិយាយអំពីឧប្បត្តិហេតុដូចធ្លាក់កេតុ មេឃក្រហមដាលឡើងក្នុងទិសផ្សេងៗនោះ និងផែនដីញ័រជាដើម ។

**៤-សុបិនំ :** តម្រាសម្រាប់ទាយយល់សប្តិ៍។

**៥-លក្ខណំ:** តម្រាសម្រាប់ទាយលក្ខណៈរបស់ស្ត្រី និងបុរស។

**៦-មូលិកច្ឆន្នំ :** តម្រាសម្រាប់ទាយនូវសំពត់ដែលកណ្តុរកាត់។

**៧-អគ្គិហោមំ :** វិធីបូជាភ្លើង។

**៨-ទព្វិហោមំ :** វិធីបូជាវែក។

ព្រមទាំងវិធីការផ្សេងៗដែលនាំឱ្យត្រៃសរណគមន៍ដាច់តួយ៉ាងដូចជាការពោលអួតនូវឧត្តរិមនុស្សធម្ម(គុណធម៌ក្រៃលែង)ដែលមិនមានក្នុងខ្លួន ដើម្បីយកទ្រនីបឬអាមិសឬរង្វាន់ខាន់ខៅ ដើម្បីចិញ្ចឹមជីវិត ឬក៏ធ្វើគ្រូហ្ម អាគម ចារគាថា គូរយ័ន្ត ស្រោចទឹក ចងខ្សែ ធ្វើពលីកម្មផ្សេងៗមានទេវពលីជាដើមដោយខ្លួនឯងឬក៏ដឹកនាំគេឱ្យធ្វើ ។ល។ ដើម្បីយកលាភសក្ការៈមកចិញ្ចឹម ជីវិត។

កាលបើសីលវន្ត-សីលវតីបានលះបង់ហើយនូវមិច្ឆាជីវៈដូចបានពោលហើយខាងលើគប្បីសមាទាននូវសម្មាជីវៈគឺការចិញ្ចឹមជីវិតត្រូវតែម្យ៉ាង។ ឯសម្មាជីវៈរបស់សីលវន្ត-សីលវតីមានលក្ខណៈគួរឱ្យកត់សម្គាល់មានដូចតទៅ:

-គ្រឿងឧបភោគ-បរិភោគ កើតឡើងតាមធម៌ គឺជនដទៃគេមានសទ្ធាជ្រះថ្លានាំមកហើយជូន។

- គ្រឿងឧបភោគ-បរិភោគដែលជាទ្រព្យសម្បត្តិរបស់ខ្លួន[១៥] ដែលខ្លួនបានប្រគល់ហើយដល់វេយ្យាវច្ចករ មុនពេលដែលខ្លួនកាន់សីល ១០ ហើយវេយ្យាវច្ចករនោះបានរៀបចំសម្រេចហើយនាំមកជូនខ្លួន។

-គ្រឿងឧបភោគ-បរិភោគដែលបានមកហើយដោយពុទ្ធបរិស័ទគេអញ្ជើញទៅដាក់បាត្រដោយសទ្ធាជ្រះថ្លា ស្មោះស្ម័គ្រក្នុងចិត្ត។

-គ្រឿងឧបភោគ-បរិភោគដែលជាទ្រព្យសម្បត្តិមួយ គឺខ្លួនបានហើយដោយកម្លាំង[១៦] (ត្បាញរវៃ គូរឆ្លាក់ ដេររ៉ាក់.....) ដែលមិនប៉ះពាល់ដោយមិច្ឆាជីវៈ ៥យ៉ាង និងតិរច្ឆានវិជ្ជា

## ១៦_ពិចារណានូវគ្រឿងឧបភោគបរិភោគ ឱ្យឃើញត្រឹមតែធាតុ

ក្នុងការពិចារណានូវគ្រឿងប្រើប្រាស់និងគ្រឿងបរិភោគដែលសីលវន្ត

---

[១៥] :គម្ពីរធម្មបទដ្ឋកថា រឿងកស្សបទាំង៣ មានឧរុវេលស្សបជាដើម ក្នុងសម័យព្រះពុទ្ធ ព្រះនាមផុស្សៈ។

[១៦] : រឿងយជិកាស្ទូនឆ្នាំ ក្នុងសម័យព្រះពុទ្ធ ព្រះនាមកស្សបៈ។

សីលវតីក្នុងព្រះពុទ្ធសាសនានេះ គប្បីពិចារណាទៅតាមរបៀបបច្ចវេក្ខណ - វិធីដូចជាសាមណេរនិងភិក្ខុដែរ ។ ព្រោះបច្ចវេក្ខណវិធី នេះជាវិធី១ សម្រាប់ឱ្យយោគាវចរ[១៧] ដែលជាអ្នកមានសេចក្តីប្រាថ្នាក្នុងការប្រតិបត្តិ ត្រង់ឆ្ពោះទៅកាន់ព្រះនិព្វាន គប្បីធ្វើដើម្បីរំដោះខ្លួនឱ្យរួចចាកអំពីរសតណ្ហា (សេចក្តីប្រាថ្នាក្នុងរស) ផោដ្ឋព្វតណ្ហា (សេចក្តីប្រាថ្នាក្នុងគ្រឿងប្រើប្រាស់ដែលប៉ះផ្ទប់នឹងកាយ) ដោយខានពុំបាន ។ កាលបើមានសេចក្តីយ៉ាងនេះ ទើបពោលថាគ្រហស្ថដែលជាសីលវន្ត-សីលវតី ជាអ្នកឃើញភ័យក្នុងវដ្ត ក្នុងការប្រើប្រាស់នូវគ្រឿងឧបភោគ-បរិភោគ ដើម្បីរួចចាកអំពីរសតណ្ហា ទៅបាននោះ លុះត្រាតែគ្រហស្ថ ជាសីលវន្ត-សីលវតី នោះពិចារណានូវគ្រឿងឧបភោគ-បរិភោគនោះឱ្យ ឃើញត្រឹមតែធាតុប៉ុណ្ណោះ (ធាតុខាងក្នុងអាស្រ័យនឹងធាតុខាងក្រៅធាតុខាងក្នុងនិងធាតុខាងក្រៅជាធាតុដូចគ្នា) ។

ក្នុងទីនេះសូមលើកយកបច្ចវេក្ខណវិធី ដែលសាមណេរ និងភិក្ខុធ្លាប់ប្រើប្រាស់ក្នុងសាសនានេះ តម្កល់ទុកដើម្បីឱ្យសីលវន្ត-សីលវតី (អ្នករក្សា

[១៧] :ភិក្ខុក្តី សាមណេរក្តី ឧបាសកក្តី ឧបាសិកាក្តី ដែលមានសេចក្តីព្យាយាមដុតកម្តៅនូវកិលេស ។

សីល១០) សម្រាប់យកមកប្រតិបត្តិពិចារណាក្នុងការប្រើប្រាស់នូវទេយ្យវត្ថុ[១៨] ទាំង៤។ សត្វទាំងឡាយក្នុងលោកសុទ្ធតែត្រូវអាស្រ័យរបស់ទាំង៤ មានសំពត់ជាដើម ទើបអាចប្រព្រឹត្តទៅបាន បើមិនអាស្រ័យនូវបច្ច័យទាំងនោះសោះទេ មិនអាចរស់នៅបានឡើយ ព្រោះហេតុនេះ របស់ទាំង៤នោះទើបបានឈ្មោះថា "បច្ច័យ"។ សីលវន្ត សីលវតី ដែលសមាទាននូវសីល ១០ដោយសទ្ធា ជាអ្នកឃើញភ័យក្នុងសង្សារវដ្ត កាលបើបានទទួល និង បរិភោគប្រើប្រាស់នូវបច្ច័យទាំង៤ ដែលកើតឡើងហើយ ត្រូវធ្វើការពិចារណា ក្នុងការទទួល និង ប្រើប្រាស់ឱ្យល្អ ឱ្យបាន សេចក្ដីបរិសុទ្ធ[១៩] ឥតមានទោស។

## ១៧-បច្ចវេក្ខណវិធី

ក្នុងបច្ច័យមួយៗ លោកពោលដោយបច្ចវេក្ខណៈ គឺលក្ខណៈសម្រាប់ពិចារណាមាន៤ គឺធាតុប្បច្ចវេក្ខណៈ១ បដិកូលប្បច្ចវេក្ខណៈ១ តង្ខណិកប្បច្ចវេក្ខណៈ១ អតីតប្បច្ចវេក្ខណៈ១។

---

[១៨] : វត្ថុ ដែលបុគ្គលជឿទៅលើកម្ម និងផល ហើយឱ្យ។

[១៩] : បច្ច័យ៤ ក្នុងទីនេះ សំដៅដល់ទេយ្យវត្ថុដែលទាយក ទាយិកា មានសទ្ធាជ្រះថ្លានាំមក ហើយជូនមិនបានពោរដល់ទ្រព្យសម្បត្តិរបស់ខ្លួនផ្ទាល់ឡើយ។

ក- **ធាតុប្បច្ចវេក្ខណៈ**

ធាតុប្បច្ចវេក្ខណៈនោះ គឺឱ្យពិចារណាក្នុងការដែលទទួលនូវ បច្ច័យ៤ ឱ្យឃើញថាជាធាតុ ។កាលដែលទទួលនូវចីវរប្បច្ច័យឱ្យពិចារណាដូច្នោះថា **យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ**

កាលដែលទទួលនូវបិណ្ឌបាតប្បច្ច័យ ឱ្យពិចារណាដូច្នោះ: **យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ បិណ្ឌបាតោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

កាលដែលទទួលនូវសេនាសនប្បច្ច័យ ឱ្យពិចារណាដូច្នោះថា: **យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ សេនាសនំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ។**

កាលដែលទទួលនូវគលានប្បច្ច័យ ឱ្យពិចារណាដូច្នោះ: **យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ**

**គន្ធបត្យញ្ជនោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ។**

## សេចក្ដីប្រែ

**យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ។**

សំពត់ចីវរឯណានេះ សំពត់ចីវរនេះ គ្រាន់ជាធាតុពិតប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គលគឺអាត្មាដែលជាអ្នកប្រើប្រាស់សំពត់ចីវរនោះក្ដី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណមានសភាពសោះសូន្យទទេ។

**យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ បិណ្ឌបាតោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ។**

ចង្ហាន់បិណ្ឌបាតនេះ គ្រាន់តែជាធាតុពិតប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគចង្ហាន់បិណ្ឌបាតនោះ

ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ។

**យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ សេនាសនំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ។**

ទីសេនាសនៈឯណានេះទីសេនាសនៈនេះគ្រាន់តែជាធាតុពិតប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគប្រើប្រាស់ទីសេនាសនៈនោះក្តីក៏គ្រាន់តែជាធាតុមិនមែនសត្វមិនមែនខ្លួនប្រាណមានសភាពសោះសូន្យទទេ។

**យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ។**

គ្រឿងបរិក្ខារជាទីរក្សានូវជីវិតគឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណានេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិតគឺថ្នាំជាបច្ច័យដល់អ្នកជំងឺនេះ គ្រាន់តែជាធាតុពិតប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគគ្រឿងបរិក្ខារ ជាទីរក្សានូវជីវិតគឺថ្នាំជាបច្ច័យដល់អ្នកជំងឺ

នោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ។

## ខ- **បដិក្ខូលប្បច្ចវេក្ខណៈ**

បដិកូលប្បច្ចវេក្ខណៈ គឺឱ្យពិចារណាក្នុងខណៈដែលប្រារព្ធនឹងបរិភោគនូវបច្ច័យ៤ ឱ្យឃើញថាជារបស់បដិកូល គួរខ្ពើមរអើម។ កាលដែលប្រារព្ធនឹងប្រើប្រាស់នូវចីវរប្បច្ច័យ ឱ្យពិចារណាដូច្នោះថា៖

**សព្វានិ បនិមានិ ចីវរានិ អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយា ជាយន្តិ។**

កាលដែលប្រារព្ធនឹងបរិភោគប្រើប្រាស់នូវបិណ្ឌបាតប្បច្ច័យ ឱ្យពិចារណាដូច្នេះថា៖

**សព្វោ បនាយំ បិណ្ឌបាតោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ។**

កាលដែលប្រារព្ធនឹងបរិភោគប្រើប្រាស់នូវសេនាសនប្បច្ច័យ ឱ្យពិចារណាដូច្នេះថា៖

**សេព្វំ បនិមានិ សេនាសនានិ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ។**

កាលដែលប្រារព្ធនឹងបរិភោគនូវគិលានប្បច្ច័យ ឱ្យពិចារណាដូច្នេះ ថា៖

**សេព្វោ បនាយំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។**

## សេចក្តីប្រែ

**សព្វានិ បនិមានិ ចីវរានិ អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយា ជាយតិ។**

សំពត់ចីវរទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក។

**សេព្វោ បនាយំ បិណ្ឌបាតោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ។**

ចង្ហាន់បិណ្ឌបាតទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក។

**សព្វានិ បនិមានិ សេនាសនានិ អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ។**

ទីសេនាសនៈទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃលែង។

**សព្វោ បនាយំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ។**

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក។

## គ- **តង្ខណិកប្បច្ចវេក្ខណៈ**

តង្ខណិកប្បច្ចវេក្ខណៈនោះ គឺឱ្យពិចារណាក្នុងខណៈដែលបរិភោគនូវបច្ច័យ៤។

កាលដែលប្រើប្រាស់នូវចីវរប្បច្ច័យ ឱ្យពិចារណាថា :

**បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ។**

កាលដែលបរិភោគនូវបិណ្ឌបាតប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

**បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវាមិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ។**

កាលដែលបរិភោគប្រើប្រាស់នូវសេនាសនប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

**បដិសង្ខា យោនិសោ សេនាសនំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ។**

កាលដែលបរិភោគនូវគិលានប្បច្ច័យ ឱ្យពិចារណាដូច្នោះថា :

**បដិសង្ខា យោនិសោ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិសេវាមិ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។**

**<u>សេចក្តីប្រែ</u>** **បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។**

សីលវន្ត-សីលវតី គប្បីពិចារណាដោយឧបាយថា : អញអាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរ កំណត់ទុកដើម្បីការពារនូវត្រជាក់ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំ

ទាំងឡាយ កំណត់ទុកដើម្បីនឹងបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្តីខ្មាសឱ្យកម្រើក ។

**បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវាមិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ។**

សីលវន្ត-សីលវតីគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគចង្ហាន់បិណ្ឌបាត ដើម្បីនឹងលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងឱ្យកើតបុរសមានៈស្រវឹងដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុកដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតិន្ទ្រិយឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារីអញនឹងកំចាត់បង់នូវវេទនាចាស់គឺសេចក្តីឃ្លានដែលមានហើយផង និងញ៉ាំងវេទនាថ្មីគឺឆ្អែត

ហួសប្រមាណមិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង៤ក្ដី សេចក្ដីមិនមានទោស មានមិនច្រអូសកាយមិនច្រអូសចិត្តជាដើមក្ដី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង៤ក្ដី នឹងមានដល់អញដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។

**បដិសង្ខា យោនិសោ សេនាសនំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ។**

សីលវន្ត-សីលវតី គប្បីពិចារណាដោយឧបាយថា អញអាស្រ័យគឺបរិភោគប្រើប្រាស់នូវសេនាសនៈ កំណត់ទុកដើម្បីនឹងការពារនូវត្រជាក់ ដើម្បីការពារនូវកម្ដៅ ដើម្បីការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្ដៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបន្ទោបង់នូវគ្រោះថ្នាក់កើតឡើងអំពីរដូវ ហើយអភិរម្យសំងំនៅក្នុងកម្មដ្ឋាន ។

**បដិសង្ខា យោនិសោ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិសេវាមិ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ។**

សីលវន្ត សីលវតីគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ កំណត់ទុក ដើម្បីនឹងការពារនូវវេទនាទាំងឡាយដែលបៀតបៀនផ្សេងៗ ដែលកើតឡើង ហើយដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា។

ឃ- **អតីតប្បច្ចវេក្ខណៈ**

អតីតប្បច្ចវេក្ខណៈនោះ គឺឱ្យពិចារណានូវបច្ច័យ៤ក្នុងអតីតកាល គឺកាលដែលបរិភោគរួចហើយ ដែលត្រូវពិចារណាបានតែក្នុងថ្ងៃនោះ គឺក្នុងវេលាយប់១ ថ្ងៃ១ កុំឱ្យអរុណរះឡើងទាន់ ហើយក្នុងបច្ចវេក្ខណៈ មួយៗពិចារណា១ចប់ ឬ ២ចប់ ៣ចប់ក៏បាន។

**អជ្ជ មយា អបច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ**

ឱសធកសទាគាគបសីរិសបសច្ចស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ។

អជ្ជ មយា អបច្ចវេក្ខិត្វា យោ បិណ្ឌបាតោ បរិភុត្តោ សោ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយា នុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ។

អជ្ជ មយា អបច្ចវេក្ខិត្វា យំ សេនាសនំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឱសធកសទាគាគបសីរិសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ។

អជ្ជ មយា អបច្ចវេក្ខិត្វា យោ គិលានបច្ចយភេសជ្ជ បរិក្ខារោ បរិភុត្តោ សោ យាវទេវ ឧប្បន្នានំ

**វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈ បរមតាយាតិ។**

## សេចក្តីប្រែ

**អជ្ជ មយា អបច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ។**

សំពត់ចីវរឯណាដែលអញមិនបានពិចារណាហើយ ប្រើប្រាស់ហើយក្នុងថ្ងៃនេះ សំពត់ចីវរនោះ អញប្រើប្រាស់កំណត់ទុកដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្តីខ្មាសឱ្យកម្រើកបាន។

**អជ្ជ មយា អបច្ចវេក្ខិត្វា យោ បិណ្ឌបាតោ បរិភុត្តោ សោ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ**

**ទិហីសុបរតិយា ព្រហ្មចរិយា នុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ។**

ចង្ហាន់បិណ្ឌបាតឯណាដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ បង្ហាន់បិណ្ឌបាតនោះ អញមិនបរិភោគដើម្បីនឹងលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងឱ្យកើតបុរិសមានៈស្រវឹងដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុកដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតន្ទ្រិយឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវវេទនាចាស់គឺសេចក្តីឃ្លានដែលមានហើយផង នឹងញ៉ាំងវេទនាថ្មីគឺឆ្អែតហួសប្រមាណមិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង៤ក្តី គឺសេចក្តីមិនមានទោសមានមិនច្រអូសកាយមិនច្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង៤ក្តី នឹងមានដល់អញដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ។

**អជ្ជ មយា អបច្ចវេក្ខិត្វា យំ សេនាសនំ បរិភុត្តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ**

**ឧំសមកសទាគាគបសិរីសបសម្ពស្សាន់ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ។**

ទីសេនាសនៈឯណាដែលអញមិនបានពិចារណាហើយ បរិភោគប្រើ-ប្រាស់ហើយក្នុងថ្ងៃនេះ ទីសេនាសនៈនោះ អញបរិភោគកំណត់ទុកដើម្បីនឹងការពារនូវត្រជាក់ ដើម្បីការពារនូវកម្តៅនិងពស់តូចពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបន្ទោបង់នូវក្រវល់ក្រវាយដែលកើតអំពីរដូវហើយអភិរម្យសំងំនៅក្នុងកម្មដ្ឋាន។

**អជ្ជ មយា អបច្ចវេក្ខិត្វា យោ គិលានប្បច្ចយភេសជ្ជបរិក្ខារោ បរិភុត្តោ សោ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈ បរមតា យាតិ។**

គ្រឿងបរិក្ខារជាទីរក្សានូវជីវិតគឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណាដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិតគឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះ អញបរិភោគកំណត់ទុកដើម្បីនឹងការពារនូវវេទនាទាំងឡាយដែលបៀតបៀនផ្សេងៗដែលកើតឡើងហើយដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា។

**ចំណាំ** ៖ បើកាលដែលទទួលនិងកាលដែលប្រារព្ធដើម្បីបរិភោគនិងកាលដែលបរិភោគនោះ បានពិចារណាដោយធាតុប្បច្ចវេក្ខណៈ ដោយបដិកូលប្បច្ចវេក្ខណៈ ដោយតង្ខណិកប្បវេក្ខណៈរួចសព្វគ្រប់ហើយ នឹងមិនបាច់ពិចារណាក្នុងអតីតប្បច្ចវេក្ខណៈទៀតក៏បានដែរ ។

## ១៨. លក្ខណៈវិនិច្ឆ័យក្នុងបច្ចវេក្ខណវិធី

ក៏បច្ចវេក្ខណវិធី គឺវិធីដែលសម្រាប់ពិចារណាក្នុងបច្ច័យមួយៗ នោះមានបួនៗ គឺក្នុងចីវរប្បច្ច័យ៤ បិណ្ឌបាតប្បច្ច័យ៤ សេនាសនប្បច្ច័យ៤ គិលានភេសជ្ជបច្ច័យ៤ ហើយមានឈ្មោះថា ធាតុប្បច្ចវេក្ខណៈ បដិកូល-ប្បច្ចវេក្ខណៈ តង្ខណិកប្បច្ចវេក្ខណៈ អតីតប្បច្ចវេក្ខណៈដូចគ្នា រួមទាំងអស់ត្រូវជាបច្ចវេក្ខណៈ១៦ ។

បច្ចវេក្ខណកាល គឺកាលដែលត្រូវពិចារណាក្នុងបច្ច័យមួយៗនោះមានបីៗ ហើយមានឈ្មោះថា បដិលាភកាល កាលដែលកំពុងបាន ឬកំពុងទទួលនូវបច្ច័យ១, បរិភោគកាល កាលដែលកំពុងប្រើប្រាស់នូវបច្ច័យ១, អតីតកាល កាលដែលបរិភោគប្រើប្រាស់កន្លងហើយ១ ដូចគ្នាគ្រប់បច្ច័យទាំង៤ រួមទាំងអស់ត្រូវជាកាល១២ ។

បណ្ដាកាលទាំង៣នោះ ក្នុងបដិលាភកាលត្រូវពិចារណាដោយធាតុប្បច្ចវេក្ខណក៏បាន បដិកូលប្បច្ចវេក្ខណៈក៏បាន ក្នុងបរិភោគកាលត្រូវពិចារណាដោយតង្ខណិកប្បច្ចវេក្ខណៈ ក្នុងអតីតកាលត្រូវពិចារណាដោយអតីតប្បច្ចវេក្ខណៈ។ ធាតុប្បច្ចវេក្ខណៈ ត្រូវពិចារណាផ្ទៀបមកជាមួយនឹងកាយរបស់ខ្លួនឱ្យឃើញថាគ្រាន់តែជាធាតុ ដើម្បីនឹងលះបង់នូវសេចក្ដីប្រកាន់ថា ខ្លួននឹងរបស់ខ្លួនរាប់បញ្ចូលក្នុងធាតុមនសិការកម្មដ្ឋាន ឬ ចតុធាតុវវដ្ឋានកម្មដ្ឋាន[២០] ។

បដិកូលប្បច្ចវេក្ខណៈ ត្រូវពិចារណាផ្ទៀបមកជាមួយនឹងកាយរបស់ខ្លួនឱ្យឃើញថា ជារបស់មិនស្អាត គួរខ្ពើមរអើម ដើម្បីនឹងលះបង់សេចក្ដីសម្គាល់ខុសថាជាល្អស្អាត ។បើក្នុងបិណ្ឌបាតប្បច្ច័យរាប់បញ្ចូលក្នុងអាហារេបដិកូលសញ្ញា[២១] ឯក្នុងបច្ច័យឯទៀតរាប់បញ្ចូលក្នុងបដិកូលមនសិការកម្មដ្ឋាន[២២] ។ តង្ខណិកប្បច្ចវេក្ខណៈ និងអតីតប្បច្ចវេក្ខណៈ ត្រូវពិចារណាឱ្យដឹងនូវដែនរបស់ប្រយោជន៍ ក្នុងការបរិភោគ ប្រើប្រាស់នូវបច្ច័យ៤

---

[២០] : មើលក្នុងសតិបដ្ឋានសូត្រ ត្រង់ធាតុបព្វ និងសមាធិនិទ្ទេស ត្រង់ចតុធាតុវវដ្ឋានកម្មដ្ឋាន

[២១] : មើលក្នុងសមាធិនិទ្ទេស ត្រង់អាហារេបដិកូលសញ្ញាកម្មដ្ឋាន ។

[២២] : មើលក្នុងសតិបដ្ឋានសូត្រត្រង់បដិកូលបព្វ ។

ដូចគ្នា មិនឱ្យសម្គាល់ប្រយោជន៍ក្នុងការបរិភោគប្រើប្រាស់ ឯអតីតប្បច្ច-វេក្ខណៈត្រូវពិចារណាបន្ថែមក្នុងកាលដែលបរិភោគ ប្រើប្រាស់រួចហើយ ក្នុងថ្ងៃដដែល ការពារក្រែងភ្លេចភ្លាំងស្មារតីមិនបានពិចារណាក្នុងកាលដែលកំពុងបរិភោគ ប្រើប្រាស់នោះ ដើម្បីនឹងបិទទ្វារក្រសែរបស់តណ្ហា មិនឱ្យសេចក្តីប្រាថ្នាជាប់ចិត្តក្នុងបច្ច័យទាំងនេះ និងប្រហារនូវឧបនិស្ស័យរបស់រាគៈ ទោសៈ មោហៈ និងមានៈជាដើម មិនឱ្យកើតឡើង ព្រោះតែបរិភោគប្រើប្រាស់នូវបច្ច័យទាំងនោះ។ កាលបើភិក្ខុបរិភោគប្រើប្រាស់នោះ មិនមែននាំយកនូវសេចក្តីសុខមកប្រគល់ឱ្យឡើយ មានតែនាំមកនូវសេចក្តីទុក្ខក្នុងអបាយមកប្រគល់ឱ្យ ដោយពិត តួយ៉ាងដូចពុទ្ធភាសិតដែលលោកអាងទុកមកដូច្នេះ :

**អយសាវ មលំ សមុដ្ឋាយ តទុដ្ឋាយ តមេវ ខាទតិ ឯវំ អតិធោនចារិនំ សានិ កម្មានិ នយន្តិ ទុគ្គតឹ ។**

សេចក្តីថា : មន្ទិលដែលតាំងឡើងអំពីដែក ចេញមកអំពីដែក ត្រឡប់ស៊ីដែកដដែលនោះវិញយ៉ាងណាមិញ អំពើកម្មទាំងឡាយដែលតាំងឡើងខាងក្នុងខ្លួន រមែងដឹកនាំនូវបុគ្គលដែលប្រព្រឹត្តកន្លងនូវប្រាជ្ញា

ជាគ្រឿងពិចារណានូវបច្ច័យ ហើយបរិភោគប្រើប្រាស់នោះឱ្យទៅកាន់ទុគ្គតិ យ៉ាងនោះឯង ។

## ១៩_ដែនរបស់ប្រយោជន៍ក្នុងការប្រើប្រាស់នូវបច្ច័យ

ក្នុងតង្ខណិកប្បច្ចវេក្ខណៈ និង អតីតប្បច្ចវេក្ខណៈ នឹងពោលត្រឹមតែតង្ខណិកប្បច្ចវេក្ខណៈ១ប៉ុណ្ណោះ ទុកជាតួយ៉ាងឯអតីតប្បច្ចវេក្ខណ មិនចាំបាច់ពោលឡើយ ព្រោះមានសេចក្តីដូចគ្នា ។

ក្នុងចីវរប្បច្ច័យកំណត់ដែនត្រឹមប្រយោជន៍ ៤យ៉ាង គឺ

**១-សីតស្ស បដិឃាតាយ** ដើម្បីការពារត្រជាក់ ។

**២-ឧណ្ហស្ស បដិឃាតាយ** ដើម្បីការពារនូវកម្តៅ ។

**៣-ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ** ដើម្បីការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ ពស់តូច និងពស់ធំទាំងឡាយ ។

**៤-ហិរិកោបិនប្បដិច្ឆាទនត្ថំ** ដើម្បីបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្តីខ្មាសឱ្យកម្រើក ។

ក្នុងបិណ្ឌបាតប្បច្ច័យ ចាត់ជាអង្គដែលត្រូវឃាត់៤ ដែលជាដែនរបស់ប្រយោជន៍៨ រួមទាំងអស់ត្រូវជាអង្គ១២ ដូច្នេះគឺ

**១-នេវ ទវាយ** មិនមែនដើម្បីលេងដូចក្មេងអ្នកស្រុក

**២-ន មទាយ** មិនមែនដើម្បីឱ្យកើតបុរិសមានះ ស្រវឹងដូចអ្នកប្រដាល់។

**៣-ន មណ្ឌនាយ** មិនមែនដើម្បីប្រដាប់តាក់តែងរាងកាយ ដូចស្ត្រីក្នុងបុរី។

**៤-ន វិភូសនាយ** មិនមែនដើម្បីស្អិតស្អាងរាងកាយឱ្យផូរផង់ពណ៌សម្បុរ ដូចអ្នកលេងរបាំ។

ទាំង៤នេះជាអង្គត្រូវឃាត់ មិនមែនជាដែនរបស់ប្រយោជន៍។

**៥-ឥមស្ស កាយស្ស ឋិតិយា** ដើម្បីនឹងតាំងនៅនៃកាយនេះ។

**៦-យាបនាយ** ដើម្បីញ៉ាំងជីវិតន្ទ្រិយឱ្យប្រព្រឹត្តទៅ។

**៧-វិហឹសុបរតិយា** ដើម្បីបំបាត់បង់នូវសេចក្តីលំបាក។

**៨-ព្រហ្មចរិយានុគ្គហាយ** ដើម្បីអនុគ្រោះដល់ព្រហ្មចរិយ។

**៩-ឥតិបុរាណញ្ច វេទនំ បដិហង្ខាមិ** ដូច្នេះអញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង។

**១០-នវញ្ច វេទនំ ន ឧប្បាទេស្សាមិ** អញនិងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឱ្យកើតឡើងបានផង។

**១១-យាត្រា ច មេ ភវិស្សតិ** កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង៤ នឹងមានដល់អញផង។

**១២-អនវជ្ជតា ច** សេចក្តីមិនមានទោស មិនច្រអូសកាយ មិនច្រអូសចិត្តជាដើម(នឹងមានដល់អញផង)។

អង្គទាំង៨នេះ ជាដែនរបស់ប្រយោជន៏ នៅមានសល់អង្គ១ទៀតគឺ **សុផាវិហារោ ច** កិរិយានៅសប្បាយក្នុងឥរិយាបថទាំង៤(នឹងមានដល់អញ)តែអង្គនេះលោកមិនបានរាប់បញ្ចូលមកផង ព្រោះលោកចាត់ជាអានិសង្សរបស់ភោជន។ បណ្តាអង្គទាំង១២ អង្គដែលត្រូវឃាត់៤ ខាងដើមសម្រាប់ប្រហារឧបនិស្ស័យរបស់កិលេស គឺអង្គទី១ សម្រាប់ប្រហារនូវឧបនិស្ស័យរបស់មោហៈ អង្គទី២សម្រាប់ប្រហារនូវឧបនិស្ស័យរបស់ទោសៈ អង្គទី៣ និងអង្គទី៤សម្រាប់ប្រហារនូវឧបនិស្ស័យរបស់រាគៈ ឯអង្គក្រៅអំពីនេះ សម្រាប់កំណត់តែដែនរបស់ប្រយោជន៏ប៉ុណ្ណោះ។

ក្នុងសេនាសនប្បច្ច័យ កំណត់ដែនត្រឹមប្រយោជន៏៥យ៉ាងគឺ

**១-សីតស្ស បដិឃាតាយ** ដើម្បីការពារនូវត្រជាក់។

**២-ឧណ្ហស្ស បដិឃាតាយ** ដើម្បីការពារនូវកម្តៅ។

**៣-ឥសិមកសរាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ** ដើម្បីការពារសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ ពស់តូច និងពស់ធំទាំងឡាយ ។

**៤-ឧតុបរិស្សយវិនោទនំ** ដើម្បីបន្ទោបង់នូវក្រវល់ក្រវាយដែលកើតអំពីរដូវ ។

**៥-បដិសល្លានារាមត្ថំ** ដើម្បីប្រមូលចិត្តអំពីអារម្មណ៍ផ្សេងៗ ហើយអភិរម្យនៅក្នុងកម្មដ្ឋាន ។

ក្នុងគិលានប្បច្ច័យ ដែនរបស់ប្រយោជន៏ កំណត់ត្រឹមតែ១ គឺ **ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។**

ដើម្បីការពារនូវទុក្ខវេទនាទាំងឡាយដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយដរាបទៅដល់ត្រឹមប្រាសចាកសេចក្តីទុក្ខ ។

ប្រយោជន៏ក្នុងការប្រើប្រាស់បច្ច័យ ត្រូវព្រះយោគីសង្ឃឹមតែត្រឹមដែនបានកំណត់ទុកមកទាំងនេះឯង មិនត្រូវសង្ឃឹមឱ្យជ្រុលហួសអំពីដែនទាំងនេះទៅឡើយ ។

## ២០-ការជម្រះសីល

យោគាវចរ ដែលជាអ្នកស្រឡាញ់សុខស្អប់ទុក្ខក្នុងសង្សារវដ្ត កាលបើសមាទាននូវសីលហើយ គប្បីសង្រួមប្រុងប្រយត្ន័កុំប្រព្រឹត្តកន្លងសិក្ខា

បទដែលខ្លួនសមាទានហើយ តែថាកាលបើមានសេចក្តីភ្លាំងភ្លាត់ដាច់សីល ណាមួយ ដោយទោសនៃសេចក្តីប្រហែសធ្វេស ត្រូវទៅប្រកាសប្រាប់អំពី ទោសកំហុសរបស់ខ្លួនចំពោះអាចារ្យ ឬ សព្រហ្មចារី ហើយសម្តែងទោស នោះហើយត្រូវធ្វើនូវសេចក្តីសង្រួមតទៅទៀត។

ការជម្រះសីល គឺជាការជម្រះកាយកម្ម វចីកម្ម និងមនោកម្មឱ្យ ស្អាតបរិសុទ្ធ ដូចមានសេចក្តីសម្តែងក្នុងគម្ពីរ **មជ្ឈិមនិកាយ** មូលបណ្ណា សកភិក្ខុវគ្គ ត្រង់ ចូឡរាហុលោវាទសូត្រទី១ថា ទឹកមានបន្តិចបន្តួចដក់ ជាប់នៅក្នុងផ្តិលយ៉ាងណា ទឹកដែលគ្មានក្នុងផ្តិល ឬ ផ្តិលទឹកដែលគេផ្កាប់ ឬ ថាផ្តិលផ្ងាររលីងដែលគ្មានទឹកយ៉ាងណា ពួកភិក្ខុដែលមិនមានសេចក្តី អៀនខ្មាសក្នុងសម្បជានមុសាវាទ (ពោលពាក្យកុហកដោយដឹងខ្លួន) មានសមណធម៌(ធម៌របស់ជនអ្នកស្ងប់) មានប្រមាណតិចក៏យ៉ាងនោះ។

ដំរីរបស់ស្តេចចូលទៅកាន់សង្គ្រាម ធ្វើការគ្រប់អវយវៈទាំងអស់ មិនមានសេសសល់ តែនៅលាក់ប្រមោយ ព្រោះខ្លាចសេចក្តីស្លាប់យ៉ាង ណា សីលវន្ត-សីលវតីបួសក្នុងព្រះពុទ្ធសាសនា ជាអ្នកមិនមានសេចក្តី អៀនខ្មាសក្នុងការពោលពាក្យកុហក សូម្បីបន្តិចបន្តួចក៏យ៉ាងនោះ។

ដំរីរបស់ស្ដេចចូលទៅកាន់សង្គ្រាម ធ្វើការគ្រប់អវយវៈទាំងអស់ មិនអាចសេសសល់ ដោយមិនខ្លាចស្លាប់យ៉ាងណាសីលវន្ត-សីលវតីជាអ្នកខ្លាចបាប បួសក្នុងសាសនានៃព្រះត្រៃតថាគត គប្បីសិក្សាថាអាត្មាអញនឹងមិនពោលពាក្យកុហកសូម្បីបន្តិចបន្តួចក៏យ៉ាងនោះ ។

ការឆ្លុះមុខនឹងកញ្ចក់ ដើម្បីមើលមុខស្អាតនិងមិនស្អាតយ៉ាងណា ជនអ្នកជម្រះកាយកម្ម វិចីកម្ម និងមនោកម្ម ត្រូវធ្វើការត្រិះរិះក្នុងឋាន៣ គឺ

១-មុននឹងប្រារព្ធធ្វើការងារ ដោយកាយ វាចា ចិត្ត ត្រូវធ្វើសេចក្ដីត្រិះរិះការងារនោះសិន តើល្អ ឬ អាក្រក់ ។

២-ពេលកំពុងធ្វើការងារដោយ កាយ វាចា ចិត្ត ត្រូវធ្វើសេចក្ដីត្រិះរិះក្នុងការងារនោះទៀត តើល្អ ឬ អាក្រក់ ។

៣-ពេលធ្វើការងារនោះហើយ ត្រូវធ្វើសេចក្ដីត្រិះរិះក្នុងការងារនោះទៀត តើល្អ ឬ អាក្រក់ ។

ប្រសិនបើធ្វើនូវសេចក្ដីត្រិះរិះក្នុងការងារនោះ ឃើញថាការងារនោះជាអកុសល( អាក្រក់) ត្រូវលះបង់ចេញឈប់ធ្វើ តែបើការងារនោះជាកុសល( ល្អ)ទេ ត្រូវព្យាយាមធ្វើចុះ ។

ម្យ៉ាងទៀតកាយកម្ម និងវចីកម្មដែលបានធ្វើកន្លងហើយ ជាអកុសលគឺខ្លួនត្រូវចូលទៅរកគ្រូ ឬ សព្រហ្មចារី ឬ ជាអ្នកប្រាជ្ញបណ្ឌិតណាមួយ ហើយសម្តែងនូវទោសកំហុសរបស់ខ្លួននោះក្នុងទីចំពោះមុខដោយកុំលាក់លៀមឡើយ កាលបើសម្តែងទោសនោះរួចហើយ គប្បីធ្វើនូវសេចក្តីសង្រួមឱ្យល្អតទៅមុខ។ បើកម្ម គឺអំពើដែលខ្លួនធ្វើរួចហើយនោះល្អទេ ត្រូវញ៉ាំងបីតិបាមោជ្ជៈ ឱ្យពោរពេញឡើងក្នុងសន្តានតទៅ។

ម្យ៉ាងទៀត សីលវន្ត-សីលវតី ដែលជម្រះសីលឱ្យស្អាតបរិសុទ្ធនោះត្រូវធ្វើខ្លួនឱ្យមានសភាពជាអ្នកប្រាថ្នាតិច សន្តោស ដុសខាត់ចិត្តគំនិតឱ្យស្អាតផូរផង់ រួចចាកអំពីមេថុនសំយោគ និងបាបធម៌លាមកមានកោធជាដើម ដោយការចម្រើននូវកម្មដ្ឋានណាមួយក្នុងព្រះពុទ្ធសាសនា។

ម្យ៉ាងទៀតក្នុងការជម្រះសីលនេះ ក្នុងគម្ពីរវិសុទ្ធិមគ្គ មានសេចក្តីបញ្ជាក់ថា : គ្រហស្ថដែលជាអ្នករក្សាសីល មានសីល១០ជាដើម បើចង់ឱ្យសីលបរិសុទ្ធ ត្រូវសមាទានធុតង្គ។ ធុតង្គសម្រាប់គ្រហស្ថ មាន២យ៉ាងគឺ ឯកាសនិកង្គ១ បត្តបិណ្ឌិកង្គ១។

-ឯកាសនិកង្គ មានន័យថា អង្គរបស់ភិក្ខុអ្នកមានកិរិយាបរិភោគនូវភោជន តែក្នុងអាសនៈ១ ជាប្រក្រតី ។

-បត្តបិណ្ឌកង្គ មានន័យថា អង្គរបស់ភិក្ខុអ្នកមានកិរិយាបរិភោគនូវភោជនតែក្នុងបាត្រ[២៣] ។

វិកិច្ចប្រតិបត្តិក្នុងធុតង្គទាំងពីរនេះ មានសរសេរទុកក្នុងសៀវភៅបឋមវិបស្សនាហើយ សូមស្រាវជ្រាវដោយខ្លួនឯងចុះ ។

## ២១_ការចម្រើនកម្មដ្ឋាន

កម្មដ្ឋានមានន័យថា ឧបាយសម្រាប់ទូន្មានចិត្តចែកចេញជាពីរយ៉ាង គឺ សមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ។ កម្មដ្ឋានទាំង២នេះ បានរៀបចំហើយ ទុកក្នុងសៀវភៅបឋមវិបស្សនា មធ្យមវិបស្សនា និងឧត្តមវិបស្សនា សូមសិលវន្ត និងសីលវតីទាំងឡាយ គប្បីស្វែងរកមើលយកមកប្រតិបត្តិដោយខ្លួនឯងចុះ ។

[២៣] : បាត្រក្នុងទីនេះ មិនសំដៅយកតែបាត្រត្រង់តែម្យ៉ាងឡើយ ទុកណាជាភាជន៍ដទៃ ក៏ហៅថាបាត្រដែរ ។

## ២២.ភាពផ្សេងគ្នារវាងសីល៨ និងសីល១០

សីល៨ លោកហៅថា អដ្ឋសីល ឬ ឧបោសថសីល ។

## ២៣. ឧបោសថសីល

ឧបោសថសីមាន ៣យ៉ាង :

**១-បកតិឧបោសថ** : ឧបោសថតាមធម្មតា

**២-បដិជាគរុបោសថ** : ឧបោសថរបស់បុគ្គលអ្នកភ្ញាក់រលឹក

**៣-បាដិហារិយុបោសថ** : ឧបោសថដែលបុគ្គលគប្បីរក្សា

-បកតិឧបោសថ ក្នុង១ខែ ពុទ្ធបរិស័ទគប្បីរក្សា ៨ ថ្ងៃ

-បដិជាគរុបោសថ ក្នុង១ខែ ពុទ្ធបរិស័ទគប្បីរក្សា ១១ថ្ងៃ

-បាដិហារិយុបោសថ ពុទ្ធបរិស័ទត្រូវរក្សាឧបោសថចំនួន១៩ថ្ងៃ ក្នុង១ខែ ពុំមានដាច់ក្នុងថ្ងៃឧបោសថណាមួយឡើយ ហើយប្រកប ដោយកាល ។ រីកាលដែលពុទ្ធបរិស័ទត្រូវរក្សានូវបាដិហារិយុបោសថនោះ បើគិតជាខែ មាន៥ខែ គឺអាសាធ ស្រាពណ៍ ភទ្របទ អស្សុជ និងកត្តិក បើគិតជាថ្ងៃមាន៤ខែ គឺចាប់ពីថ្ងៃបុគ្គលត្រូវរក្សានូវបាដិហារិយបោសថ នោះឱ្យគ្រប់ ថ្ងៃនៃបក្ខនោះទើបបានបុណ្យ ប្រសិនណាបើក្នុងបក្ខនោះ

បុគ្គលរក្សានូវឧបោសថមិនគ្រប់ថ្ងៃទេ បាដិហារិយុបោសថត្រូវដាច់ សោះសូន្យ មិនបានបុណ្យឡើយ ។

**ឧទាហរណ៍:** តួយ៉ាងដូចជាឧបាសកម្នាក់ រក្សានូវបាដិហារិយុឧបោសថ ក្នុងរដូវវស្សាចំនួន១ខែ គឺរាប់ពីថ្ងៃ ១រោច ខែអាសាធ ដល់ថ្ងៃ ១៥កើត ខែស្រាពណ៍ក្នុងពេលរក្សានោះ ស្រាប់តែឧបាសកនោះភ្លេចស្មារតីធ្វើឱ្យដាច់ ឧបោសថសីលក្នុងថ្ងៃណាមួយ ក្នុងចំណោមនៃថ្ងៃឧបោសថ ១ខែនោះ តាមគម្ពីរមង្គលត្ថទីបនីបញ្ជាក់ថា ឧបាសកនោះត្រូវដាច់បាដិហារិយុបោ - សថសីលដែលខ្លួនបានរក្សាហើយក្នុង១ខែនោះទាំងអស់ ដូច្នេះឧបាសក នោះដែលខំប្រឹងចំណាយពេលរក្សាបាដិហារិយុបោសថសីលនោះ គ្មានបាន បុណ្យសោះឡើយ ។

**បុច្ឆា:** បានឮថាឧបោសថសីលក្នុង១ខែមាន១៩ថ្ងៃ នៅសល់ថ្ងៃអំពីនោះ តើពុទ្ធបរិស័ទត្រូវរក្សាសីលអ្វី?

**វិសជ្ជនា** : តាមគម្ពីរមង្គលត្ថទីបនីបានបញ្ជាក់ថា : ក្នុង១ខែ ៣០ថ្ងៃ ចំនួន១៩ថ្ងៃ ដូចបានពោលហើយខាងលើ បើពុទ្ធបរិស័ទមានសទ្ធាគប្បី រក្សាឧបោសថសីលឱ្យបានគ្រប់ថ្ងៃទាំងអស់ជាការប្រសើរ ក្រៅពី១៩ថ្ងៃ ១កើត ២កើត ៣កើត ១០កើត ១១កើត ១២កើត ២រោច ៣រោច

១០រោច ១១រោច ១២រោច ប្រសិនបើជាថ្ងៃខែដាច់ ១៤រោច មានតែ ១០ថ្ងៃគឺជាថ្ងៃបញ្ចសីល ( សីល៥ ) ។

សីល៨ មានសិក្ខាបទ៨[២៤] រីឯសីល១០ មានសិក្ខាបទ១០ លើសអំពីសីល៨ ត្រង់សិក្ខាបទទី១០ **ជាតរូបរជតបដិគ្គហនា វេរមណី :** ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវមាសនិងប្រាក់។

អ្នករក្សានូវឧបោសថសីលអាចកាន់ហើយប្រើប្រាស់នូវមាសនិងប្រាក់បាន រីឯអ្នករក្សាសីល១០ មិនអាចកាន់ទុកដាក់នូវមាស និងប្រាក់បានឡើយ ព្រោះទំនាស់នឹងសិក្ខាបទទី១០។

**ប្រស្នា** : មនុស្សក្នុងលោកអាស្រ័យនូវមាសនិងប្រាក់សម្រាប់ទិញដូរចំណាយផ្សេងៗចុះបើអ្នករក្សាសីល១០ វៀរចាកមាសនិងប្រាក់ដូច្នេះ តើរស់នៅដូចម្ដេចបាន?

**វិសជ្ជនា** : អ្នករក្សាសីល១០ វៀរចាកមាសនិងប្រាក់ក៏ពិតមែនហើយ តែក៏អាចរស់នៅបានដូចជាគ្រហស្ថដទៃដែរ ព្រោះថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់បញ្ញត្តនូវសិក្ខាបទ មិនឱ្យអ្នករក្សាសីល១០ កាន់មាស និងប្រាក់ តែទ្រង់បានអនុញ្ញាតឱ្យអ្នកកាន់នូវសីល១០នោះ ត្រេកអរនឹងប្រើ

---

[២៤] :មានក្នុងបឋមវិបស្សនា

ប្រាស់នូវបច្ច័យទាំង៤ មានសំពត់ជាដើម ដែលសម្រេចអំពីមាស និង ប្រាក់ដែលទុកដាក់ហើយក្នុងដៃវេយ្យាវច្ចករក្នុងសម័យមុនពេលដែលខ្លួន កាន់សីល១០ ឬ ក្នុងសម័យដែលកំពុងកាន់សីល១០ ហើយមានទាយក ទាយិកាគេនាំមកនូវមាសនិងប្រាក់នោះ ហើយគេបវារណានូវបច្ច័យ ទាំង៤ ហើយគេទុកដាក់ក្នុងដៃវេយ្យាវច្ចករ ។

**បុច្ឆា** : អ្នករក្សាសីល១០ មិនទទួលទុកដាក់នូវមាស និងប្រាក់ដោយខ្លួន ឯង ចុះប្រសិនបើគេឱ្យទុកដាក់ចំ៧ តើមានកំហុសដែរឬទេ?

**វិស្សជ្ជនា** : ប្រាកដជាមានកំហុស ព្រោះសិក្ខាបទនេះ លោកបាន បញ្ញត្តថាអ្នករក្សាសីល១០ ទោះជាទុកដាក់ដោយខ្លួនឯងក្តី ឬ ក៏ប្រើគេ ចំ៧ឱ្យទុកដាក់នូវមាសនិងប្រាក់នោះដើម្បីខ្លួនឈ្មោះថាមានកំហុសដូចគ្នា ។

**បុច្ឆា** : ខ្ញុំដូចជាឆ្ងល់ណាស់នូវពាក្យខាងដើមបានពោលថាបើទុកជាអ្នក កាន់សីល១០ មិនទទួលទុកមាសនិងប្រាក់ក៏អាចរស់នៅបាន តើបាន អ្វីយកទៅទិញគ្រឿងឧបភោគ-បរិភោគ សម្រាប់បម្រុងជីវិត?

**វិស្សជ្ជនា** : មិនបញ្ហាអ្វីឡើយ បើទុកជាមិនកាន់មាសនិងប្រាក់ដោយ ខ្លួនឯង ឬ មិនបានប្រើចំ៧ឱ្យជនដទៃទុកដាក់មាសប្រាក់សម្រាប់ខ្លួន នោះ ក៏អាចដោះស្រាយបញ្ហាជីវិតបាន ព្រោះថា **ទិនះយោ ភិច្ច គម្ពីរោ**

វិន័យជ្រៅដោយកិច្ច សីលវន្ត និងសីលវត្តទាំងឡាយ កាលបើមានសទ្ធាជ្រះថ្លារក្សានូវសីល១០ ត្រូវស្គាល់ប្រមាណនៃខ្លួន គឺត្រូវទុកដាក់មាសនិងប្រាក់នោះដល់ជនណាម្នាក់ ដែលគេចង់បានបុណ្យកុសលឱ្យគេទិញដូរសម្រេចឱ្យ។ ម្យ៉ាងទៀត នៅក្នុងសម័យដែលខ្លួនកាន់សីល១០ មានទាយកនិងទាយិកាគេនាំមាសនិងប្រាក់មកជូន ត្រូវនិយាយដោយវិន័យកិច្ចថាៈ ម្នាលអ្នកដ៏ចម្រើនខ្ញុំសព្វថ្ងៃនេះកំពុងតែរក្សានូវសីល១០ មិនអាចទទួលដាក់មាសនិងប្រាក់បានឡើយ។ កាលបើទាយក-ទាយិកា គេសួរថា : បពិត្រលោកយាយ លោកតាដ៏ចម្រើន តើនរណាជាវេយ្យាវច្ចកររបស់លោក។ ក្នុងពេលនោះអ្នករក្សានូវសីល១០ គប្បីចង្អុលបង្ហាញនូវវេយ្យាវច្ចកររបស់ខ្លួន ដោយពោលថាគាត់នោះជាវេយ្យាវច្ចកររបស់ខ្ញុំ។ កាលបើទាយក-ទាយិកានោះបានជ្រាបដូច្នោះហើយក៏បានជម្រាបតា និងយាយសីល១០ថា បើដូច្នេះសូមលោកតា ឬក៏លោកយាយ គប្បីចងចាំទុកថា ខ្ញុំសុំជូនមាសនិងប្រាក់ចំនួនប៉ុណ្ណេះ តែខ្ញុំទុកដាក់លើវេយ្យាវច្ចកររបស់លោក បើសិនជាលោកត្រូវការទេយ្យវត្ថុទាំងឡាយ៤ មានសំពត់ ម្ហូបអាហារ ប្រដាប់ប្រើប្រាស់ផ្សេងៗ ឬក៏

គិលានភេសជ្ជៈសូមអញ្ជើញទៅយកបច្ច័យពីវេយ្យាវច្ចករបស់លោក ឱ្យគេសម្រេចឱ្យ។

**បុច្ឆា** : មាស និងប្រាក់ដូចម្ដេចហ្ន៎? ដែលមានកំហុសដល់អ្នកសីល១០។

**វិស្សជ្ជនា** : គឺមាស និងប្រាក់ជារបស់ខ្លួនផ្ទាល់ ដែលខ្លួនកាន់យកក្តី ឬប្រើឱ្យគេកាន់ជំនួសខ្លួនក្តី ឈ្មោះថាមានកំហុសដូចគ្នា។

**បុច្ឆា** : ចុះប្រសិនបើមាសនិងប្រាក់ ដែលគេបវារណាទុកដាក់ក្នុងវេយ្យាវច្ចករហើយ តែវេយ្យាវច្ចករនោះកេងប្រវ័ញ្ច បន្លំយកទៅចាយវាយប្រើប្រាស់ផ្សេងៗ មិនសម្រេចប្រយោជន៍ដល់អ្នកកាន់សីល១០ តើសីលវន្ត-សីលវតីគិតដូចម្ដេច?

**វិស្សជ្ជនា** : បើសិនជាមិនបានសម្រេចប្រយោជន៍ដល់ខ្លួននោះ សីលវន្ត-សីលវតី អាចទៅប្រាប់ដល់ម្ចាស់ដើមវិញថា ទេយ្យវត្ថុ ដែលអ្នកបវារណាដល់ខ្ញុំហើយទុកដាក់ក្នុងដៃវេយ្យាវច្ចករ មិនបានសម្រេចជាប្រយោជន៍ដល់ខ្លួនខ្ញុំឡើយ។

**បុច្ឆា** : ចុះរូបិយដែលជាម្ចាស់ និងប្រាក់នោះ មានតម្លៃទូលំទូលាយយ៉ាងណាខ្លះ? និងប្រាក់សុទ្ធក្តី ធ្វើអំពីវត្ថុដទៃមានក្រដាសក្តី ដូចជាក្រដាសប្រាក់រៀល ឬក្រដាសប្រាក់ដុល្លារជាដើម ដែលគេកំណត់សម្រាប់

ប្រើប្រាស់ក្នុងការទិញដូរសម្រាប់ចិញ្ចឹមជីវិត ក៏ឈ្មោះថារូបិយដូចមាស និងប្រាក់សុទ្ធដែរ។ ដូច្នេះសីលវន្ត-សីលវតីក្នុងព្រះពុទ្ធសាសនានេះ ទុកជាកាន់មាស និងប្រាក់សុទ្ធក្តី ឬក៏ក្រដាសប្រាក់ ឬក៏វត្ថុណាមួយទុកជាដែក ឬ ស្ពាន់ ឬ ឈើ។ល។ នៅក្នុងសង្គមមនុស្សដែលគេកំណត់ថាជារូបិយ សម្រាប់ទិញដូរ ចាយវាយផ្សេងៗ ឈ្មោះថាមានកំហុសទាំងអស់។ សិក្ខាបទនេះមាន អង្គ៣គឺ

- រូបិយ
- ជារបស់ខ្លួន
- បានទទួលកាន់យកខ្លួនឯង ឬប្រើអ្នកដទៃទៃចំៗ[២៥]

**<u>បុច្ឆា</u>** : អ្នករក្សាឧបោសថសីល ចុះប្រសិនបើគេរក្សានូវសីល ៨ នោះរៀងរាល់ថ្ងៃ មិនថាថ្ងៃឧបោសថ ឬថ្ងៃមិនមែនឧបោសថរៀងរាល់ខែ និងរៀងរាល់ឆ្នាំ តើមានកំហុសដែរឬទេ?

**<u>វិសជ្ជនា</u>** : មិនមានកំហុសអ្វីឡើយព្រោះថាអ្នករក្សានូវឧបោសថសីល នោះគេរក្សាប្រកបដោយកុសលចេតនា។ អើ ! ថ្ងៃណាដែលជាថ្ងៃ

---

[២៥] :ពាក្យថាចំៗនោះគឺសំដៅយកការពោល ប្រើជនដទៃឱ្យគេទុកដាក់មាសប្រាក់ លុយកាក់សម្រាប់ខ្លួនតែម្តង មិនបានប្រើវិន័យកិច្ចដូចបានពោលខាងលើ។

ឧបោសថ ថ្ងៃនោះនឹងជាថ្ងៃឧបោសថដោយពិត រីឯថ្ងៃដទៃមិនមែនជាកាលនៃថ្ងៃឧបោសថមានថ្ងៃ១កើតជាដើម ថ្ងៃនោះមិនអាចប្រកាន់ពាក្យថាជាថ្ងៃឧបោសថសីលបានឡើយ ព្រោះទំនាស់នឹងពុទ្ធបញ្ញត្តិ មានពាក្យថា **អដ្ឋមី ចាតុទ្ទសី** ឬក៏ **បណ្ណរសី**ជាដើម។ ប្រសិនបើឧបាសក-ឧបាសិកា ទាំងឡាយដែលមានសទ្ធាជ្រះថ្លារក្សានូវសិក្ខាបទ៨ ដែលមិនមែនជាថ្ងៃឧបោសថ ត្រូវតម្កល់ចិត្តថាអញរក្សានូវសិក្ខាបទ៨ យកបុណ្យកុសលតែប៉ុណ្ណោះ តែមិនត្រូវនិយាយប្រកាន់ថា ថ្ងៃណាក៏ជាថ្ងៃឧបោសថដែរនោះទេ។

## ២៣~របៀបស្លៀកពាក់

ឧបាសក-ឧបាសិកា ដែលរក្សានូវនិច្ចសីល(សីល៥) ឧបោសថសីល (សីល៨) ដែលជាបកតិឧបោសថ ហើយអាស្រ័យនៅក្នុងពុទ្ធមណ្ឌល មជ្ឈមណ្ឌល ឬក៏មណ្ឌលវិបស្សនាធុរៈ ដើម្បីគោរពប្រតិបត្តិចម្រើនសមថកម្មដ្ឋាននិងវិបស្សនាកម្មដ្ឋានគួរស្លៀកសំពត់ខ្មៅ អាវស ពានាក្រមា ស រីឯសក់ទុកក៏បាន កោរក៏បាន។ អ្នករក្សានូវបាដិហារិយុបោសថ ឬក៏សិក្ខាបទ៨រៀងរាល់ថ្ងៃ រៀងរាល់ខែ រៀងរាល់ឆ្នាំឬក៏រហូតដល់អស់មួយជីវិតអាស្រ័យនៅក្នុងពុទ្ធមណ្ឌល មជ្ឈមណ្ឌល ឬមណ្ឌលវិបស្សនា-

ធុរៈ ដើម្បីគោរពប្រតិបត្តិចម្រើនសមថកម្មដ្ឋាននិងវិបស្សនាកម្មដ្ឋាន គួរប្រើប្រាស់សម្លៀកបំពាក់ពណ៌សសុទ្ធ ត្រូវកោរសក់ កោររោមចិញ្ចើម កាត់ក្រចកដៃ-ជើង ឱ្យស្មើនឹងសាច់ម្រាមដៃ-ជើង។

សីលវន្ត-សីលវតី អ្នកឃើញភ័យក្នុងវដ្ត ហើយមានសទ្ធាជ្រះថ្លាដ៏មុតមាំ លះបង់ខ្ពស់រក្សានូវសីល១០ យកតម្រាប់តាមសាមណេរ ត្រូវប្រើប្រាស់សម្លៀកបំពាក់ពណ៌សសុទ្ធ ហើយត្រូវស្លៀកពាក់តាមបែបផែនដូចតទៅ:

**ផ្នែកបុរស** : ស្លៀកសំពត់ ពាក់អាវកាក់ រៀលក្បៀក ពាក់ឆៀងស្មាម្ខាង ហើយគ្រងសំពត់ធំ ពានាពីខាងក្រៅ។

**ផ្នែកស្ត្រី** : ស្លៀកសំពត់ ពាក់អាវដៃវែង គ្រងសំពត់ ពានាពីខាងក្រៅ។

## ២៤-កិច្ចវត្ត

សីលវន្ត-សីលវតី កាលបើមានសទ្ធាជ្រះថ្លារក្សានូវសីល១០ តាមការនិយមរបស់ខ្លួន[២៦] ត្រូវកោរសក់ រោមចិញ្ចើម ពុកមាត់ ពុកចង្កា កាត់ក្រចកដៃ-ជើងឱ្យខ្លី ឱ្យត្រឹមស្មើនឹងសាច់ម្រាមដៃ-ជើង ស្លៀក

[២៦] :ពាក្យថា និយម សំដៅយកការកាន់សីលតាមកំណត់ មានកន្លះខែ ឬ ១ខែជាដើម ។ល។

ដណ្តប់សំពត់កាសាយៈដូចបានពោលខាងលើ កាន់ទៀននិងធូបសម្រាប់អុជបូជាព្រះរតនត្រ័យ ត្រូវមានកិច្ចដូចតទៅ :

- នមស្ការព្រះរតនត្រ័យ
- សូមខមាទោស
- ថ្វាយខ្លួនជាឧបាសក-ឧបាសិកា
- សមាទាននូវសីល១០(និយមសីលឬ អតិរេកសីល)
- សុំទីជ្រកអាស្រ័យ ប្រគល់អាទិភាពឱ្យលោកអាចារ្យ
- រៀនកម្មដ្ឋាន

កិច្ចទាំងអស់នេះ បានសរសេរទុកហើយក្នុងបឋមវិបស្សនា ចូរស្រាវជ្រាវសិក្សាចុះ ។

## អវសានកថា

អាត្មាភាពមានសេចក្តីសង្ឃឹមថា សៀវភៅ "**វិន័យសីល១០**" នេះ និងបានជាគុណប្រយោជន៍ដល់ពុទ្ធសាសនិកជនទាំងឡាយដោយពិត ម្យ៉ាងទៀតសូមអភ័យទោសអំពីសំណាក់អ្នកអានទាំងឡាយ បើសិនជាមានភ្លាំងភ្លាត់ដោយអក្ខរា ឬ ដោយន័យត្រង់ណានីមួយៗ ដែលប្រាសចាកពីពុទ្ធដីការដោយអចេតនា ហើយសូមប្រគេនពរនិងជូនពរដល់

ព្រះករុណា សាធុជនអ្នកអានទាំងអស់ សូមឱ្យកើតមានប្រាជ្ញាមោះមុត ដើម្បីកម្ចាត់នូវគ្រឿងមន្ទិលពីខន្ធសន្តាន ហើយសូមឱ្យបានប្រកបដោយពរទាំង៥ប្រការគឺ អាយុះ វណ្ណះ សុខះ ពលះ និងបដិភាណះ កុំបីឃ្លៀងឃ្លាតឡើយ ។

--- ---